# ទស្សនាវដ្ដី
# សាស្ត្រាចារ្យ

BIBLIOTHEQUE NATIONALE

## សួស្ដីឆ្នាំថ្មី!



ផ្សាយចេញ
រាល់
ត្រីមាស
ពី

**សមាគម**
**សាស្ត្រាចារ្យខ្មែរ**

ទីស្នាក់ការ
លេខ ១២៣ E វិថីព្រះសីហនុ ភ្នំពេញ

ខែមករា - កុម្ភៈ - មីនា
ឆ្នាំទី ៦

លេខ
1/17



# ក្នុងឱកាស ឆ្នាំថ្មីនេះ គណៈកម្មាធិការ នាយក នៃ ស.ស.ខ.

សូមប្រសិទ្ធិទូវពរសព្ទសាធុការដ៏ប្រសើរសព្វបែបយ៉ាងជូនមិត្តព្រមទាំងគ្រួសារទាំងអស់ សូមឲ្យបានប្រកបតែនឹងសេចក្ដីសុខហើយនឹងសេចក្ដីចំរើនជាដរាបតរៀងទៅ ដើម្បីនឹងធ្វើភាគទានឲ្យបានជាអតិបរមា ក្នុងកិច្ចការកសាងជាតិយើង !

សូមអានក្នុងទំព័របន្ទាប់សេចក្ដីថ្វាយព្រះពរចំពោះ :

- សម្ដេចព្រះមហាក្សត្រិយានី
- សម្ដេចព្រះប្រមុខរដ្ឋ
- សម្ដេចព្រះសង្ឃរាជទាំងពីរព្រះអង្គ



## TELEGRAMME

Le 25 mars 1965, notre Comité Directeur a adressé à Sa Majesté la Reine un télégramme dont voici la teneur :

**SAMDECH PENN NOUTH**
**Ambakhmer Paris**

Le Comité Directeur de l'Association des Professeurs Khmers et tous ses membres forment des vœux fervents de prompt rétablissement à Sa Majesté la Reine et La prient de daigner croire en leur profonde affection.

A ce télégramme, Samdech Penn Nouth nous répond en ces termes :

NR 121 Sa Majesté la Reine très touchée par vos vœux me charge vous transmettre ses affectueux remerciements et ses pensées les meilleurs stop final PENN NOUTH

# ព្រះពរឆ្នាំថ្មី

(១០ មេសា ១៩៦៥)

នៅឱកាសចូលឆ្នាំថ្មីនេះ ទូលព្រះបង្គំទាំងឡាយជាសមាជិកគណៈកម្មាធិការនាយកនៃសមាគមសាស្ត្រាចារ្យខ្មែរ

សូមបួងសួងដល់ទេវតាឆ្នាំថ្មី សូមព្រះពរជ័យពេកាសប្រសិទ្ធថ្វាយព្រះអង្គ នូវពរសព្ទសាធុការដ៏វិសេសវិសាល ដើម្បីព្រះមហាជោគជ័យសិរីមង្គលវិបុលសុខគ្រប់ប្រការ ដើម្បីទ្រង់ជាម្លប់ដ៏ត្រជាក់នៃកូនចៅព្រះអង្គជាដរាបតរៀងទៅ ។

ដោយពិធីចូលឆ្នាំថ្មីឆ្នាំនេះបានធ្លាក់មកចំឱកាសចំរើនព្រះជន្មព្រះអង្គគំរប់៦២ព្រះវស្សាផង ទូលព្រះបង្គំទាំងឡាយសូមឆ្លៀតឱកាសនេះបួងសួងដល់ទេវតាឆ្នាំថ្មី សូមទ្រង់ប្រទានពលានុភាពថ្វាយព្រះអង្គ សូមព្រះអង្គទ្រង់ជាសះស្បើយព្រះរោគបានយ៉ាងឆាប់រហ័ស ហើយសូមទ្រង់ប្រកបដោយព្រះជន្មាយុជាងរយព្រះវស្សា ដើម្បីទ្រង់បានគង់ជាព្រះមាតាជាតិ ដឹកនាំកូនចៅដើរលើផ្លូវបង្រួបបង្រួមជាតិ ឆ្ពោះទៅកាន់វឌ្ឍនភាពតរៀងទៅ។

សូមអានព្រះសារលិខិតឆ្លើយតបនៅទំព័រទី ៦ បន្ទាប់ពីនេះ



“សូមសម្តេចឪ ទ្រង់ប្រកបដោយព្រះសុខភាពដ៏បរិបូណ៌ !”

## សេចក្តីថ្វាយព្រះពររបស់យើង

(១០ មេសា ១៩៦៥)

នៅឱកាសចូលឆ្នាំថ្មីនេះ ទូលព្រះបង្គំទាំងឡាយជាសមាជិកគណៈកម្មាធិការនាយកនៃសមាគមសាស្ត្រាចារ្យខ្មែរ

សូមព្រះរាជវរោកាសប្រសិទ្ធិពរសព្ទសាធុការដ៏វិសេសវិសាលថ្វាយព្រះអង្គ សូមព្រះអង្គទ្រង់ស្ថិតនៅតែក្នុងព្រះសុខមាលភាព ព្រះសុខភាពដ៏បរិបូណ៌ ដើម្បីទ្រង់ជាម្លប់ដ៏ត្រជាក់ត្រជុំនៃកូនចៅព្រះអង្គទាំងប្រាំមួយលាននាក់ ។

ទូលព្រះបង្គំទាំងឡាយ សូមបួងសួងជាថ្មីម្តងទៀតដល់ពពួកទេព្តាឆ្នាំថ្មី សូមផ្សព្វផ្សាយនូវព្រះតេជានុភាពថ្វាយព្រះអង្គ ដើម្បីទ្រង់គង់នៅជាបង្កូតនាវាកម្ពុជា ក្នុងដំណើរឆ្ពោះទៅរកសេចក្តីសុខ-ចំរើននឹងក្នុងការពារឧបសគ្គផ្សេងៗដែលពួកមារសត្រូវ ចក្រពត្តិអាមេរិកាំងនឹងបរិវារបង្កបង្កើតឡើង ។



សម្ដេចព្រះសំឃរាជថ្នាក់ទី១

# ព្រះពរឆ្នាំថ្មីថ្វាយ

នៅឱកាសចូលឆ្នាំថ្មីនេះ ទូលព្រះបង្គំទាំងឡាយជាសមាជិកគណៈកម្មាធិការនាយក នៃសមាគមសាស្ត្រាចារ្យខ្មែរ

*សូមប្រសិទ្ធិថ្វាយព្រះអង្គ នូវពរមហាជោគជ័យសេរីមង្គលវិបុលសុខគ្រប់ប្រការ សូមទេព្ដាឆ្នាំថ្មីផ្សព្វផ្សាយនូវព្រះតេជានុភាព រក្សាការពារព្រះអង្គឲ្យបានស្ថិតនៅតែក្នុងព្រះសុខមាលភាពដ៏ប្រណីតប្រកបដោយព្រះសុខភាពដ៏បរិបូណ៌ ដើម្បីទ្រង់ជាម្លប់ដងៃកូនចៅពុទ្ធសាសនិកទាំងប្រាំមួយលាននាក់ក្នុងការគ្រាច់លើមាគ៌ាបង្រួបបង្រួមជាតិ ឧបត្ថម្ភព្រះពុទ្ធសាសនា និងកសាងជាតិឆ្ពោះទៅរកវឌ្ឍភាព ។*

(ថ្ងៃ ១០ មេសា ១៩៦៥)

... នឹងសម្ដេចព្រះសំឃរាជថ្នាក់ទី២ ដែលមានជ័យជូបគ្នា

ចំពោះព្រះពរនេះ សម្ដេចព្រះសំឃរាជថ្នាក់ទី២ ទ្រង់សព្វព្រះរាជហឫទ័យឆ្លើយតបមួយចេតទៅ :



សម្តេចព្រះសង្ឃរាជថ្នាក់ទី២

ចំរើនពរមកលោក កែ គឹមហួត ជំណាងប្រធាននៃសមាគមសាស្ត្រាចារ្យខ្មែរ

សូមជ្រាប ។

អាត្មាភាពមានសេចក្តីសោមនស្សជាអតិបរមា ចំពោះសព្ទសាធុការពរដ៏ប្រសើរ ដែលសមាជិកគណៈកម្មាធិការនាយកនៃសមាគមសាស្ត្រាចារ្យខ្មែរបានប្រសិទ្ធដោយមេត្តាចិត្ត ថ្វាយទៅអាត្មាភាព ដើម្បីសិរីមង្គល វិបុលសុខគ្រប់យ៉ាង ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីនេះ ។

អាត្មាភាព ក៏សូមជូនតបវិញនូវសព្ទសាធុការពរ ដល់លោក-អ្នកទាំងឡាយ ដោយមេត្តាចិត្តដ៏បរិសុទ្ធ គឺសូមឲ្យតេជៈគុណព្រះរតត្រ័យទាំង៣ប្រការ និងទេវតាដែលមានមហិទ្ធិឫទ្ធិសក្តិសិទ្ធិគ្រប់ស្ថាន មានទេព្តានាឆ្នាំថ្មីជាដើម ជួយអភិបាលទំនុកបំរុងទ្រទ្រង់លោកអ្នកទាំងឡាយ ឲ្យបានប្រកបដោយវឌ្ឍនភាពគ្រប់យ៉ាង និងពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ ព្រមទាំងមានសិរីសួស្តីសុភមង្គលវិបុលសុខដ៏ប្រសើរជានិច្ចនិរន្តតរៀងទៅ ។

សម្តេចព្រះសុធម្មាធិបតី ព្រះសង្ឃរាជថ្នាក់ទី២

# ញត្តិ

## • ប្រឆាំងនឹងកាសែតលោកសេរី "ញូវីក" ដែលហ៊ានប្រមាថដល់ព្រះមាតាជាតិ

## • ប្រឆាំងនឹងចក្រពត្តិអាមេរិក-វៀតណាមខាងត្បូង ដែលទំលាក់គ្រាប់បែកសម្លាប់ជនជាតិខ្មែរ

ដើម្បីនឹងសំដែងនូវកំហឹងរបស់ខ្លួនចំពោះសេចក្ដីព្រហើន និងឧបាយកលបំបែកបំបាក់សាមគ្គីភាពរបស់កាសែតលោកសេរី ហើយដើម្បីប្រឆាំងនឹងចក្រពត្តិអាមេរិកព្រមទាំងរដ្ឋការវៀតណាមខាងត្បូងដាបវិភរ ដែលទើបនឹងទំលាក់គ្រាប់បែកសម្លាប់បងប្អូនយើងនៅភូមិអន្លង់ក្រស់ក្នុងពេលថ្មីៗនេះ គណៈកម្មាធិការនាយកបានធ្វើញត្តិមួយច្បាប់ថ្វាយសម្ដេចព្រះប្រមុខរដ្ឋ កាលពីថ្ងៃ ៣០ មេសា ១៩៦៤ នេះ ។

*ដោយបានស្ដាប់ព្រះរាជសាសន៍របស់សម្ដេចឪ ដែលទ្រង់បានថ្លែងនៅវត្តសុវណ្ណសាគរ និងបានស្ដាប់ការផ្សាយតាមវិទ្យុជាតិជាហូរហែមក*

*ទូលព្រះបង្គំទាំងឡាយ សូមសំដែងនូវកំហឹងយ៉ាងរំជួលចិត្តជាទីបំផុត ចំពោះទស្សនាវដ្ដីញូវីក មានបែរណាគ្រីសិជាដើម ដែលហ៊ានផ្សាយអត្ថបទមានលក្ខណៈមួលបង្កាច់ធ្វើឲ្យប៉ះពាល់ដល់ព្រះកិត្តិនាមយ៉ាងឧត្តុង្គឧត្ដមនៃព្រះមហាក្សត្រិយានី ព្រះមាតាជាតិ ។ ការផ្សាយដំណឹងមួលបង្កាច់បែបនេះជាអំពើទាល់ច្រក អំពើថោកទាបព្រៃផ្សៃ ផ្ទុយពេញទីពីសីលធម៌ ពីច្បាប់ទំលាប់អន្តរជាតិ ។ អំពើដ៏ថោកទាបនេះបង្ហាញកាន់តែច្បាស់ថា ក្នុងបំណងសំរេចបទឧក្រិដ្ឋរបស់វា ចក្រពត្តិអាមេរិកាំងនិងបរិវារបានបណ្ដាក់គ្នាជាហូរហែមិនចេះចប់សោះ ។ ជួនកាលរដ្ឋការវាចេញមុខធ្វើសកម្មភាពខ្លួនឯង ជួនកាលវាឲ្យអ្នកកាសែតវាបំពេញមុខងារ ជួនកាលវាឲ្យ "ខ្មែរសេរី" និងបរិវារខាងក្រៅធ្វើការ ជួនកាលវាឲ្យបរិវារខាងក្នុងប្រតិបត្តិផែនការ ជួនកាលវាធ្វើស្រួល ជួនកាលវាទំលាក់គ្រាប់បែក ហើយជួនកាលទៀតវាប្រើឧបាយទាំងនេះព្រមគ្នាទាំងអស់តែម្ដង ។*

*ទូលព្រះបង្គំទាំងឡាយ សូមគាំទ្រយ៉ាងម៉ឺងម៉ាត់នូវសេចក្ដីសំរេចប្រកបដោយព្រះប្រាជ្ញាញាណនិងដោយសេចក្ដីអង់អាចក្លាហានរបស់សម្ដេចឪ ដែលមិនព្រមទទួលសេចក្ដី*

ស្នើរបស់ចក្រពត្តិអាមេរិកាំង និងអង់គ្លេស ស្តីពីការកោះប្រជុំសន្និសីទដើម្បីពិភាក្សាពីប្រទេសកម្ពុជា ។ ដូចសម្តេចឪបានវែកញែកបំភ្លឺកូនចៅរបស់ព្រះអង្គរួចមកហើយ សេចក្តីស្នើរបស់ចក្រពត្តិអាមេរិកាំង-អង់គ្លេសនេះជាឧបាយកលបំភាន់មតិខ្មែរនិងមតិសាកលលោក ដោយយកបញ្ហាប្រទេសខ្មែរយើងធ្វើជា “នុយ” ដើម្បីបានឱកាសពិភាក្សាពីបញ្ហាវៀតណាម ប្រយោជន៍នឹងយិតយោងមុខមាត់ពួកវា ដែលកំពុងតែលិចលង់យ៉ាងអាម៉ាស់នៅក្នុងភក់វៀតណាមខាងត្បូង មួយថ្ងៃៗកាន់តែជ្រៅទៅៗនោះ ។

ម្យ៉ាងទៀត ខ្ញុំព្រះបង្គំទាំងឡាយសូមសំដែងនូវសេចក្តីក្រេវក្រោធយ៉ាងខ្លាំង ចំពោះចក្រពត្តិអាមេរិកាំងនិងរដ្ឋការវៀតណាមខាងត្បូងជាបរិវារ ដែលបានបញ្ជាឲ្យយន្តហោះប្រដេញ “ស្កាយរ៉ៃដើរ” បួនគ្រឿងមកទំលាក់គ្រាប់បែកនិងបាញ់រះលើប្រជារាស្ត្រដ៏ស្លូតត្រង់របស់យើងនៅភូមិអន្លង់ត្រស់ ខេត្តកំពង់ចាម កាលពីព្រឹកថ្ងៃពុធ២៨ មេសា ម៉ោង៦គេះៗ ការទំលាក់គ្រាប់បែកយ៉ាងព្រៃផ្សៃនេះឋិតនៅក្នុងផែនការដ៏ទូលំទូលាយដែលបានរៀបចំយ៉ាងច្បាស់លាស់ដើម្បីបំផ្លាញនយោបាយអព្យាក្រឹត សន្តិភាពរបស់ប្រទេសខ្មែរ ដែលពួកវាធ្លាប់បានអនុវត្តតាំងពីយូរយារណាស់មកហើយ ដូចជាការដាក់គ្រាប់បែកក្នុងព្រះបរមរាជវាំង ការគប់គ្រាប់បែកតាមផ្លូវពោធិចិនតុង ផែនការរដ្ឋប្រហារដាប ឈួន ការទំលាក់គ្រាប់បែកនៅភូមិចន្ទ្រា, តាអឺ, ធ្លកជាដើម ។ អំពើឈ្លានពានបែបនេះសឲ្យឃើញកាន់តែច្បាស់ថា ពួកចក្រពត្តិអាមេរិកាំងនិងបរិវារទាំងប៉ុន្មាន ទាំងបរិវារក្នុង ទាំងបរិវារក្រៅ សុទ្ធតែជាសត្រូវពិតប្រាកដរបស់ប្រជាជាតិខ្មែរ ។

អាស្រ័យហេតុនេះ ខ្ញុំព្រះបង្គំទាំងឡាយសូមចូលរួមជាមួយនឹងពួកបាតុករ នៅរាជធានីភ្នំពេញនិងនៅខេត្តនានា ជាមួយនឹងប្រជាពលរដ្ឋទាំងមូល

ដើម្បីសូមស្នើឲ្យព្រះរាជរដ្ឋាភិបាលដាក់ទណ្ឌកម្មយ៉ាងតឹងរឹង និងសមរម្យដល់ពួកចក្រពត្តិអាមេរិកាំង

១– ដោយសូមឲ្យព្រះរាជរដ្ឋាភិបាលបិទទ្វារប្រទេសកម្ពុជាលែងឲ្យពួកអ្នកសារព័ត៌មានទឹងទេសបរក្លែងក្លាយមកពី "លោកសេរី" ជាពិសេសគឺអាមេរិកាំងចេញចូលតទៅទៀត;

២– ដោយសូមឲ្យព្រះរាជរដ្ឋាភិបាលផ្តាច់ចំណងទូតយ៉ាងរួសរាន់ជាមួយសហរដ្ឋអាមេរិក ពីព្រោះស្ថានទូតអាមេរិកាំងនៅប្រទេសកម្ពុជា គ្មានបំរើនូវផលប្រយោជន៍នៃប្រជារាស្ត្រប្រទេសទាំងពីរសោះឡើយ ហើយគ្មានមុខងារអ្វីក្រៅពីធ្វើសំបុកចារបុរស ដើម្បីបំផ្លាញប្រជាជាតិខ្មែរយើងតែម្យ៉ាងប៉ុណ្ណោះទេដូចជាព្រឹត្តការណ៍ "ដាប ឈួន – ម៉ាត់ ស៊ូ" ជាកស្តុតាងស្រាប់ ។

ទូលព្រះបង្គំទាំងឡាយ សូមសំដែងជាថ្មីម្តងទៀត នូវស្វាមីភក្តិចំពោះព្រះមហាក្សត្រិយានីព្រះមាតាជាតិជានិមិត្តរូបនៃព្រះរាជបល្ល័ង្ក ចំពោះសម្តេចឪនឹងចំពោះព្រះរាជនយោបាយសន្តិភាព បង្រួបបង្រួមជាតិ នឹងវឌ្ឍនភាពរបស់ព្រះអង្គ ហើយសូមប្តេជ្ញាដង្ហែតាមព្រះរាជមាគ៌ានេះ លុះដល់ជោគជ័យនៅទីអវសាន ។ សេចក្តីគួរពុំគួរសូមទ្រង់ព្រះមេត្តាប្រោស

តពីទំព័រមុន

តបនឹងសេចក្តីថ្វាយព្រះពររបស់យើងកាលពីថ្ងៃ ១០ មេសា

សម្តេច ប៉ែន នុត បានផ្ញើយមកគណៈកម្មាធិការនាយកយើងដូចតទៅ :

Paris le 17 avril 1965

សម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិតលើត្បូង ព្រះអង្គបានសព្វព្រះរាជហឫទ័យទទួលដោយរីករាយនូវព្រះពរដែលសមាជិកគណៈកម្មាធិការនាយក នៃសមាគមសាស្ត្រាចារ្យខ្មែរបានប្រសិទ្ធិថ្វាយព្រះអង្គក្នុងឱកាសចូលឆ្នាំថ្មីនេះ ។

ព្រះអង្គសព្វព្រះរាជហឫទ័យត្រាស់បង្គាប់ឲ្យខ្ញុំថ្លែងជូនមកវិញនូវសេចក្តីកតញ្ញូតាធម៌របស់ព្រះអង្គព្រមទាំងពរសព្វសាធុការដែលព្រះរាជទានមកកូនចៅទាំងអស់ សូមឲ្យបានប្រកបតែនឹងសេចក្តីសុខចំរើនកុំបីឃ្លាតឡើយ ។

ហត្ថលេខា ប៉ែន នុត

# NOUVEL AN

Les fêtes du Nouvel-An sont pour les Cambodgiens, celles de «l'entrée dans l'année nouvelle» Chaul Chhnam thmei. Mais en réalité, il y a deux «entrées», chaul, l'une basée sur la marche de la lune et marquant un changement dans le cycle des douzes animaux, l'autre calculée d'après la marche du soleil et marquant le début de l'année civile. Comme la première «entrée» a toujours lieu le premier jour du mois de chèt, tandis que la seconde, variable par rapport aux phases de la lune, coincide avec le 12 ou, plus souvent, le 13 avril, l'espace compris entre les deux «entrées» est plus ou moins long suivant les cas.

Ainsi en 1949, l'année du rat finissait, et l'année du bœuf commençait, le premier jour de la quinzaine claire de chèt, soit le 30 mars, tandis que l'année 1311 de la Petite Ere, et, pour le calendrier civil, l'an 2492 de l'Ere bouddhique commençaient le 13 avril, soit le 15 lune croissante de chèt.

Seule, de nos jours, la seconde «entrée» est solennellement fêtée, les astrologues royaux décident si les célébrations doivent durer trois ou quatre jours : mais le rite le plus important, celui des phnom khsach «monts de sable» peut commencer dès le début de chèt et s'accomplir tout le mois. Les monts de sable, dit-on le plus souvent — car les traditions varient — doivent représenter les grandes montagnes de la cosmologie indienne avec, au centre, le Mont-Meru, axe du monde, les autres étant situées aux points cardinaux et intercardinaux. La tradition lettrée veut que le «mont» central symbolise le Preah Cholamoni, stupa céleste où furent enfermés les cheveux que le Buddha coupa quand il quitta la vie princière. Comme pour bien des coutumes anciennes, il y a de nombreuses explications du rite. La plus populaire raconte par une légende comment chaque grain de sable, déposé par le fidèle délivre d'un pêché.

Les phnom-khsach sont entourés d'une enceinte à quatre portes exactement orientées. En dehors de celles-ci, des autels aux divinités de l'espace sont érigés aux points cardinaux et intercardinaux. Un neuvième autel, doublant celui de la divinité régente de l'est, est destiné à Preah Yumoreach, l'Auguste Yâma Roi, le dieu des enfers.

A Phnom-Penh, quelques jours avant les célébrations du Nouvel-An, le roi prend part à la cérémonie des «monts de sable» sur la terrasse de la pagode située au sommet de la petite éminence qui donne son nom à la ville et que la tradition associe à sa fondation. Là s'élève un grand stupa qui fut bâti au début du XVème siècle par le roi Ponhea Vat. Un bangskaul a lieu près de ce stupa et de ceux, plus petits, qui se trouvent au pied de la butte. Le bangskaul est une prière en l'honneur des morts, où l'officiant se trouve en relation avec le cadavre, le cercueil ou le reliquaire (en l'espèce le stupa) au moyen d'une bande d'étoffe qu'il tient en priant.

En outre, des «monts de sable» sont élevés dans la Pagode d'Argent, celui du centre occupant l'intérieur du temple. Le Roi fait solennellement une triple circumambulation autour de ces «monts», puis y jette une poignée de sable blanc apporté de Longvêk et y plante fleurs et oriflammes. La famille royale et les hauts dignitaires l'imitent, mai avec du salle roux du Mékong. Le rite se termine par la récitation de textes sacrés par les bonzes, auxquels sont présentés des vêtements de bain.

Cette érection de «monts de sable» n'a pas une date fixe par rapport aux cérémonies royales du Nouvel-An dont l'ordonnance n'est pas d'une rigueur absolue. (1)

Le premier jour du Chaul Chhnam est appelé sangkran, du sanskrit sangkranti signifiant «marche». C'est alors que le soleil entre dans un nouveau signe du zodiaque.

Selon une curieuse légende; qui symbolise d'anciennes conceptions astronomiques, Kabal Moha Proum (2) posa trois énigmes à un grand sage nommé Thamabal(3). S'il n'y trouvait pas réponse, Thamabal serait décapité, mais s'il réussissait, Kabal s'engageait à avoir la tête coupée. Thamabal eut la chance d'entendre, avant la date fixée, un couple d'aigles discuter des énigmes, et put donner les réponses. Kabal devait donc subir la décollation. Mais sa tête, en touchant la terre, l'aurait brûlée tout entière; jetée dans les cieux, elle aurait à jamais empêché la pluie; plongée dans l'Océan, elle l'aurait tari jusqu'à la dernière goutte. Kabal fit venir ses sept filles pour leur recommander de prendre garde, et de recevoir la tête sur un plateau. Ayant dit, il se trancha le chef, et le tendit à son ainée, Tungsa. Depuis lors, chacune des sept filles, à tour de rôle, porte la tête sur un plateau d'or et fait ainsi le tour du Mont meru pendant soixante neati, c'est-à-dire une journée entière(4). Suivant que le sangkran tombe en tel ou tel jour de la semaine, c'est l'une ou l'autre des sept déesses qui, montée sur l'animal qui lui est propre, et portant la tête de son père, conduit la procession des dieux et des déesses autour du Meru. Ainsi, lorsque le sangkran tombe un dimanche, Tungsa mène le cortège, montée sur un garuda.

L'infuence de la déesse conductrice du cortège des dieux le jour du sangkran s'étend sur toute l'année et les almanachs annoncent le bonheur ou le malheur qui s'ensuivront. Au moment du sangkran, le Roi arrive son des conques devant l'autel dressé en face de la salle du trône, pour saluer les di-

---

(1) En 1949, les rites des «monts de sable» eurent lieu avant «l'entrée dans l'annee nouvelle», les 4 et 5 avril au Phnom, les 8 et 9 avril à la Pagode d'Argent — le 4 et le 8 étant consacrés à la fabrication des «monts» à laquelle n'assiste pas le souverain.

(2) Suivant l'étymologie, Kapila le Grand-Brahmane :

(3) En sanskrit, Dharmapâla, Gardien de la Loi; le mot dhar ma désignant aussi bien la loi morale (c'est le nom que les bouddhistes donnent à l'enseignement de leur Maître) que l'ordre qui régit les phénomènes physiques.

(4) De nos jours, le neati est assimilé à la minute.

vinités gardiennes du monde et du royaume. Le Chef des Astrologues les invoque en pâli, les priant d'accorder au Roi et à la Cour, aux fonctionnaires et à tout le peuple khmer la santé, le bonheur, la paix et l'abondance. De nouveau, le Roi salue, tandis que, par trois fois, les bakou sonnent les conques (1) et l'orchestre joue, par trois fois, l'air Sathukar (bonne action).

Le rite suivant, dans l'ordre habituel des cérémonies, est le bain du Roi, au moment fixé par les hora. On remplit d'eau, bénite par des moines bouddhiques, un grand vase de bronze posé sur un support. Au pied de ce support, le roi, vêtu de blanc, s'assied face au «souffle de vie» dont la direction change suivant le jour de la semaine, le «souffle de mort» venant toujours en sens exactement contraire. Le chef des bakou, puise de l'eau dans le vase et la verse sur le souverain puis lui présente, dans une conque, un peu d'eau dont il s'humecte la figure et les cheveux. Cependant le bakou récite une formule pour éloigner les malheurs.

Ce même jour, le Roi asperge d'eau parfumée les statues des Panhcha Ksetr, qui sont les dieux Civa, Nârâyana, Baladêva, Ganeça et Uma.

Le dernier jour de fête est nommé lœung sakd et considéré comme celui où l'on entre définitivement dans la nouvelle année. Au Palais le Roi asperge d'eau parfumée l'image du Bouddha et préside au bain des bonzes qui, ensuite, célèbrent le bangskaul pour les morts de la famille royale.

Ce même jour, princes et princesses, fonctionnaires de la capitale et leurs femmes, viennent souhaiter bonheur et longue vie à leur Souverain, lui présentant des fleurs du parfum, et des bougies en nombre correspondant à leur rang.

Naguère, tous devaient prêter serment, ce qu'ils faisaient à nouveau six mois plus tard(2) et, au cours d'un grand défilé militaire, des bakou aspergaient d'eau bénite les quatre corps d'armées. Ensuite avaient lieu des courses d'éléphants, puis de chevaux, des combats entre hommes et éléphants, des matchs de boxe et de lutte. (3)

Partout dans le Cambodge dans l'enceinte des monastères ou dans les enclos des maisons, s'élèvent de «monts de sable». Chez les particuliers, ils sont de dimensions réduites, et placés sur une sorte de table; dans la région de Siemreap, où les «monts», particulièrement raffinés, ont une forme de stupa, ceux qui sont ainsi faits en miniature sont aussi élégants que les plus imposants de ce qu'on voit dans les pagodes. Dans cette même région, les phnom khsach se font auprès des banians, arbres vénérés parce que, sous l'un d'eux, le Bouddha obtint l'Illumination. Là, si l'on ne fait pas la grande cérémonie, avec 5 ou 9 «monts» entourés d'une enceinte ouverte aux points cardinaux, chaque banian est doté de sa petite montagne particulière, où le fidèle pique des bannières de papier, des bougies et des baguettes d'encens,

---

(1) Les rites royaux sont toujours soulignés par le bruit des conques trois fois répété; nous ne le mentionnerons plus à l'avenir.

(2) Actuellement, il n'y a plus qu'une prestation de serment, coincidant avec l'anniversaire du Roi.

(3) Seule subsistent les séances de boxe, devant la salle du trône. En dehors de l'enceinte du Palais, des divertissements sont offerts au peuple.

et dépose quelques offrandes.

Mais la plupart du temps on élève des «monts de sable» dans les pagodes, généralement dans l'après-midi, la veille du jour fixé pour la fête; ceux qui n'ont pu participer à leur fabrication jettent plus tard, à leur base, quelques poignées de sable. Le matin les fidèles prient, puis offrent le riz aux bonzes, avant de faire trois fois, en procession, le tour des monts. Alors, le maître de cérémonies fait une invocation, demandant le bonheur et la santé pour tous, puis les fidèles piquent leurs bannières de papier, baguettes d'encens, au pied des «monts» qu'ils aspergent d'eau parfumée ou d'eau mêlée de safran.

Les variantes sont nombreuses : c'est ainsi que dans tel village les «monts» sont faits de paddy, de riz cru, de riz cuit, de gâteau.

Très souvent, dans l'après-midi, les fidèles baignent les bonzes : ailleurs, ils baignent les statues du Bouddha en demandant que les pluies soient abondantes.

Pendant ces jours de fête ont lieux de nombreux jeux qui, le plus souvent, opposent une troupe féminine à une troupe masculine : les plus fréquents sont le jeu de chhoung, où l'on se renvoie une balle faite d'une écharpe roulée, tout en échangeant des chansons, et celui d'angkunh du nom de grosses graines dures et légèrement aplaties, qui servent de quilles.

Il existe, pour le Nouvel-An, des coutumes locales particulières. C'est ainsi que dans les régions de Siemreap, Battambang et Pursat ont lieu ce qu'on appelle les «danses de trot». Des troupes de villageois s'en vont quêter de porte en porte, en dansant et chantant. L'un d'eux chevauche un bâton courbe, portant à l'une des extrémités un massacre de cerf, et à l'autre un long panache d'herbes sous lequel pend une clochette; deux hommes masqués feignent de tuer le «cerf» de leurs fusils de bois. Le produit des quêtes est apporté à la pagode.

Dans la province de Kandal, on peut également citer des coutumes particulières. A tel village situé sur le Mekong, deux groupes de pirogues à l'intérieur de temple : le rite dit-on, était destiné à précipiter les crocodiles qui, jadis, étaient nombreux. Dans tel autre village les génies demeurant dans des arbres proches de la pagode, prennent posession de leurs desservants, pour promettre aux habitants le bonheur et la prospérité.

Partout où se dressent les ruines de temples datant de la puissance khmère, les Cambodgiens ont coutumes de se réunir au Nouvel-An. Des milliers de personnes, dans leurs plus beaux atours viennent ainsi chaque Nouvel-An, dans les ruines d'Angkor-Wat, prier et festoyer, reprenant pour quelques heures, contact avec les splendeurs du passé.

«COMMISSION DES MŒURS ET COUTUMES DU CAMBODGE»

សូមជំរាបមិត្តទាំងឡាយ

គណៈកម្មាធិការនាយក សូមសំដែងអំណរគុណចំពោះសេចក្ដីយកចិត្តទុកដាក់របស់មិត្ត ក្នុងការធ្វើសមាគមរបស់យើងឱ្យមានការរីកចំរើនទៅមិនឈប់ឈរ *(គិតមកដល់ថ្ងៃ ១៤ មេសា ១៩៦៥ សមាជិកដែលមិត្តតំណាងបានឆ្លើយតបនឹងលិខិតជំរឿនរបស់យើងមានចំនួនមួយពាន់មួយរយប៉ែតសិបនាក់)* ។

ដើម្បីនឹងធ្វើសមាគមរបស់យើងឱ្យកាន់តែល្អតលាស់ថែមទៀត

- សូមមិត្តជួយផ្ដល់អត្ថបទផ្សេងៗ សំរាប់ទស្សនាវដ្ដី
- សូមផ្ដល់ដំណឹងសុខទុក្ខនៃមិត្តយើង
- សូមប្រមូលភាគទានផ្ញើមកឱ្យបានទៀងទាត់
- សូមផ្ញើបញ្ជីជំរឿនត្រឡប់មកវិញ
- សូមបញ្ចេញមតិស្ដាបនាចំពោះទស្សនាវដ្ដីយើង

*(ការយឺតយូរបណ្ដាលមកពីបញ្ហាបច្ចេកទេស)*

# ការសិក្សានៅប្រទេស កូរ៉េប្រជាធិបតេយ្យ ប្រជាមានិត

## សិស្សនឹងនិស្សិតមានចំនួន១ភាគ៤នៃប្រជាជន

នៅប្រទេសកូរ៉េ ប្រជាជនទូទៅបានទទួលការធានាយ៉ាងពិតប្រាកដ ចំពោះការសិក្សាផ្សេងៗ

នៅសម័យដែលប្រទេសឋិតក្រោមការសង្កត់សង្កិនបរទេស ការសិក្សាយឺតយ៉ាវណាស់ៗ បក្រពត្តិជប៉ុន បានអនុវត្តនយោបាយអាណានិគមនិយមល្ងចប្ញូន នយោបាយធ្វើឲ្យមហាជនល្ងង់ខ្លៅ (politique d'obscurantisme) នឹងនយោបាយបំផ្លាញវប្បធម៌ជាតិកូរ៉េៗ ព្រោះហេតុ



នៅបណ្ណាល័យសំរាប់កុមារ
ក្នុងសង្កាត់ អូអេស៊ឹង
ព្យុងយ៉ាង

នេះហើយ បានជាជនជាតិកូរ៉េភាគច្រើនដ៏លើសលុប បានធ្លាក់ចូលទៅក្នុងរណ្ដៅអត់ឃ្លាន ហើយយុវជននឹងក្មេងៗកូរ៉េទាំងឡាយដែលគ្មានមធ្យោបាយរៀនសូត្រ ក៏ស្ថិតនៅជាមនុស្សមិនចេះអក្សរ ។ ហេតុការណ៍នេះ ទោះបីនៅក្រោយពេលរំដោះជាតិក៏ដោយ ក៏បានបង្កើតជាឧបសគ្គមួយដ៏ធំ ក្នុងការកសាងសេដ្ឋកិច្ច វប្បធម៌របស់ប្រទេស នឹងក្នុងការកសាងជីវភាពថ្មីរបស់ប្រជាជន ។



ខាងស្ដាំ នាង គី ជា

ហេតុនេះហើយ បានជាចាប់តាំងពីថ្ងៃដំបូងនៃការរំដោះមក គេបានចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើការអប់រំប្រជាជន នឹងទៅលើការបង្កើតអ្នកគ្រប់គ្រង (cadres) ។

ដំបូងដែរ រដ្ឋាភិបាលបានចាប់កែទម្រង់ការសិក្សាឲ្យមាន លក្ខណៈប្រជាធិបតេយ្យ (réforme démocratique) រួចហើយកំទេចចោលនូវប្រព័ន្ធសិក្សា នឹងអប់រំដ៏ទុគ្គត ដែលចក្រពត្តិជប៉ុនបានយកមកអនុវត្ត ដើម្បីជាគុណប្រយោជន៍ដល់ការជិះជាន់អាណានិគមនិយមរបស់ខ្លួន ។ បន្ទាប់មកទៀត ក្រោយពេល កំទេចការរើសអើង ក្នុងការអប់រំ (discrimination dans l'éducation) មក រដ្ឋាភិបាលបានធានាកប់រងចំពោះមហាជនទូទៅនូវសិទ្ធិរៀនសូត្រ ដែលស្ថិតលើស្មារតីសមភាព ដោយពុំគិតប្រកាន់ពីទ្រព្យធន ពីជំនឿ ពីភេទសោះឡើយ ។ រួចហើយរដ្ឋាភិបាលព្យាយាមកែខៃប្រព័ន្ធសិក្សា ដោយលំអនូវខ្លឹមសារនៃការអប់រំឱយបានស្របជាមួយនឹងការរីកចំរើននៃសង្គម ជាពិសេសស្របជាមួយនឹងផលិតកម្ម ។

សព្វថ្ងៃនេះ ស្ថាប័នទាំងឡាយនៃការសិក្សានៅកូរ៉េ បានបង្កើតនូវប្រព័ន្ធមួយដ៏ពេញលក្ខណៈ (système intégral) :



ស្រីស្ដីនឹង ការបង្កើតផល នេះជាវត្ថុពីរ ដែលមិនអាចផ្ដាច់ចេញពីគ្នាបាន សំរាប់និស្សិតនៅវិទ្យាស្ថានសូវៀតនៅណាំប៉ូ

— សួនកុមារ
— បឋមសិក្សា ៤ ឆ្នាំ
— មធ្យមសិក្សា ៣ ឆ្នាំ
— សាលាតិកនិកពី ២ ទៅ ៣ ឆ្នាំ
— សាលាតិកនិកជាន់ខ្ពស់ ២ ឆ្នាំ
— សាកលវិទ្យាល័យពី ៤ ទៅ ៥ ឆ្នាំ
— កម្មសិក្សានិក្ខេបបទបរិញ្ញាប័ត្រ ៤ ឆ្នាំ ( stage de thèse de licence )
— កម្មសិក្សា និក្ខេបបទថ្នាក់បណ្ឌិត ២ ឆ្នាំ

ម្យ៉ាងទៀត អ្នកធ្វើការអាយុច្រើន អាចនឹងទទួលការសិក្សាបាននៅ សាលាសំរាប់មនុស្សធ្វើការ ២ ឆ្នាំ នឹងនៅ សាលាមធ្យមសិក្សាសំរាប់អ្នកធ្វើការ ៣ ឆ្នាំ ។

ពេលចេញពីសាលាតិកនិកមក គេអាចនឹងទទួលការសិក្សាពេលល្ងាច ឬការសិក្សាតាមការទាក់ទង (par correspondance) ក្នុងសាលាជាន់ខ្ពស់ ដោយពុំចាំបាច់ចាកចោលកន្លែងធ្វើការរបស់ខ្លួនឡើយ ។

គឺយ៉ាងដូចនេះហើយ បានជាជនទាំងឡាយអាចនឹងឈោងចាប់ការសិក្សានៅក្នុងប្រទេសបានគ្រប់ៗគ្នា ។ សព្វថ្ងៃនេះសិស្សនិងនិស្សិតមានចំនួន ១ភាគ ៤ នៃចំនួនមហាជន ។

ក្នុងឆ្នាំ ១៩៦៣ មានអ្នកបច្ចេកទេស និងអ្នកឯកទេសថ្មីៗ ចំនួនជាង ៤០.០០០ នាក់ ក្នុងសម័យជប៉ុនជិះជាន់ មានអ្នកបច្ចេកទេស និងអ្នកឯកទេសតែបន្តិចបន្តួចប៉ុណ្ណោះ ។

នៅដំណាច់ឆ្នាំ ១៩៦៣ គេបានឃើញអ្នកបច្ចេកទេស និងអ្នកឯកទេសមួយទ័ព មានចំនួនជាង ២២៣.០០០ នាក់ ។

## ប្រព័ន្ធនៃការសិក្សាកាតព្វកិច្ចទូទៅ

ក្រោយរំដោះ គេបានប៉ងនឹងដាក់ឲ្យអនុវត្ត ចាប់ពីឆ្នាំ ១៩៥០មក នូវប្រព័ន្ធសិក្សាកាតព្វកិច្ចក្នុងផ្នែកបឋមសិក្សា (Enseignement primaire obligatoire) ហើយគេក៏បានរៀបចំប្រដាប់ប្រដាសព្វគ្រប់ ដើម្បីការនេះ ។

ក្រោយមក ក្មេងដល់អាយុរៀនស្ទើរតែទាំងអស់ បានចូលទៅក្នុងសាលា ។ ប៉ុន្តែចំបាំងរុករានបង្កដោយចក្រពត្តិអាមេរិក (១៩៥០-១៩៥៣) បានបង្ខំប្រទេសកូរ៉េ ឲ្យលើកការអនុវត្តិរបៀបសិក្សានេះដាក់ទៅថ្ងៃក្រោយទៀត ។

ការសិក្សាបែបនេះ ទើបបានត្រូវស្ថិតជាធរមាន ចាប់ពីឆ្នាំ ១៩៥៦មក គឺ ៣ ឆ្នាំក្រោយការបញ្ចប់សង្គ្រាមតែប៉ុណ្ណោះ ។ ហើយ ២ ឆ្នាំក្រោយមកទៀត គឺក្នុងឆ្នាំ ១៩៥៨ ប្រព័ន្ធសិក្សាកាតព្វកិច្ចមធ្យមសិក្សា ក៏បានដាក់ឲ្យអនុវត្តតមកទៀតដែរ ។

ការសិក្សាកាតព្វកិច្ចនេះ បានអនុវត្តទៅចំពោះក្មេងទាំងអស់គ្មានរើសមុខ ។ ជាឧទាហរណ៍ មានសាលាមួយនោះត្រូវបានសង់ឡើង ជាដំបូងដើម្បីនឹងទទួលក្មេង ១៣ នាក់ ដែលជាកូនអ្នកកាប់ឈើ នៅដំបន់ដាច់ស្រយាលមួយ ។

សព្វថ្ងៃនេះ រដ្ឋាភិបាលបានបំពេញដោយជោគជ័យនូវការរៀបចំ ការសិក្សាកាតព្វកិច្ចខាងតិកនិក មានរយៈពេលពី ២ ទៅ ៣ ឆ្នាំ បន្ថែមលើការសិក្សាកាតព្វកិច្ចខាងបឋម និងមធ្យមសិក្សារយៈពេល ៧ ឆ្នាំ ថែមទៀត ។

## ប្រទេសដែលមិនស្គាល់ការចេញសោហ៊ុយសិក្សា

ក្នុងប្រទេស នៅសាលាគ្រប់ជាន់ថ្នាក់ ការសិក្សាប្រព្រឹត្តទៅដោយគ្មានបង់ថ្លៃឡើយ ហើយម្យ៉ាងទៀត រដ្ឋាភិបាលបានធានា តាមគ្រប់មធ្យោបាយដែលអាចធ្វើបាននូវលក្ខខណ្ឌផ្សេងៗ ដើម្បីការសិក្សាសំរាប់សិស្សនិងនិស្សិតទាំងអស់ ។

ក្រោយពេលរំដោះភ្លាមមក រដ្ឋាភិបាលបានអនុញ្ញាតពុំឲ្យក្មេងៗ កូនអ្នកក្រទាំងឡាយបង់ថ្លៃសិក្សា ហើយបានផ្តល់ឲ្យទទេ នូវប្រដាប់ប្រដាសិក្សា និងវត្ថុប្រើប្រាស់ទូទៅ ហើយថែមទាំងបានបង្កើន នូវចំនួនក្មេងទទួលការអនុគ្រោះបែបនេះ ឲ្យមានកាន់តែច្រើនឡើងៗទៀតផង ។

កាលពីខែមេសា ១៩៥៩ រដ្ឋាភិបាលបានលុបបំបាត់តម្លៃសិក្សាសព្វបែបយ៉ាង ៗ ចំណែកឯការបង់លុយចូលរៀន ( droit d'admission ) វិញក៏បានសូន្យជីវិតជាមួយនឹងកំណើតនៃការរំដោះទៅដែរ ។

លើសពីនេះទៅទៀត រដ្ឋបានផ្តល់ចំពោះសិស្សនិងនិស្សិតនូវឯកសណ្ឋាននិងអាវកុត (paletots) សៀវភៅរៀន និងប្រដាប់សិក្សាផ្សេងៗទៀត ។ មិនតែប៉ុណ្ណោះ គេនៅបានទទួលអាហាររូបករណ៍ មិនបាច់សងវិញរបស់រដ្ឋថែមទៀតផង ។

សិស្សនិងនិស្សិតគ្មានគ្រួសារ ក្នុងនោះមានសិស្សនិងនិស្សិតដែលមកពីកូរ៉េខាងត្បូង បានបើកពីរដ្ឋនូវអាហាររូបករណ៍

– ពិសេស ហើយបានទទួលដោយឥតបង់ថ្លៃនូវវត្ថុប្រើប្រាស់ចាំបាច់ផ្សេង សំរាប់ការរស់នៅរៀងរាល់ថ្ងៃ ៗ រដ្ឋាភិបាលមានការឈឺឆ្អាលយ៉ាងជ្រាលជ្រៅ ចំពោះការអប់រំក្មេងៗ កូនអាណិកជនជាតិកូរ៉េនៅប្រទេសជប៉ុន; រដ្ឋាភិបាលបានផ្ញើប្រាក់ទៅឲ្យគេ ចំនួន ១៤ ដងមកហើយ ចាប់ពីខែមេសា ១៩៥៧ មកទល់នឹងខែមេសា ១៩៦៤ សំរាប់ការអប់រំដ៏ច្រើន ដែលមានចំនួនទាំងអស់ដល់ទៅ ៣.១៩៦.៥៧០.០០០ យេន (ប្រាក់ជប៉ុន)។

# ដើម្បីការលូតលាស់ដ៏សុខដុមនៃមនុស្ស



សិស្សក្នុងពេលរៀន

ការសិក្សានៅកូរ៉េមានលក្ខណៈស្របនឹងការទាមទារនៃសម័យកាល ហើយដំរង់ទិសទៅបណ្ដុះមនុស្សឲ្យមានការលូតលាស់ដ៏សុខដុម ( développement harmonieux ) ។ ទាំងខាងផ្នែកចំណេះចេះដឹង ផ្នែកសីលធម៌ និងទាំងផ្នែកសុខភាព ក្នុងការសិក្សាទាំងអស់ ក្មេងៗជំនាន់ថ្មីត្រូវបានអប់រំ ដើម្បីឲ្យទៅជាអ្នកស្ថាបនាដ៏វិសេសនៃវឌ្ឍនភាព និងសង្គមនិយម ។

កិច្ចការបង្រៀន និងអប់រំ នៅគ្រប់សាលា ត្រូវបានរៀបចំដ៏ផ្ចិតផ្ចង់យ៉ាងណា លុះត្រាតែចំណេះទាំងឡាយដែលបានផ្ដល់ដល់សិស្ស អាចនឹងបានយកមកប្រើប្រាស់ជាក់ស្ដែងក្នុងការរស់នៅ ហើយលុះត្រាតែសិស្សចេះធ្វើការបែបបដិវត្តន៍ ដើម្បីមាតុភូមិ និងដើម្បីមហាជន ។

ក្នុងសាលា គេបានបញ្ចូលលាយឡំគ្នានូវការអប់រំខាងសីលធម៌ ខាងសញ្ចេតនា និងខាងរូបកាយ ព្រមជាមួយនឹងការផ្ដល់នូវចំណេះទូទៅដ៏ទូលាយ ។ ចំណែកខាងការគុបតែងមេរៀន នៅបឋមសិក្សា និងមធ្យមសិក្សា ជាពិសេស មេរៀនអំពីសិល្បៈនិងមុខរបរ ក៏ដូចជាមេរៀនអំពីកាយសិក្សា បានទទួលនូវសារៈសំខាន់មួយយ៉ាងធំ ។ សកម្មភាពផ្សេងៗ នៅក្រៅសាលា ឬក្រៅថ្នាក់រៀន (en dehors de l'école et de la classe) សុទ្ធតែបានទទួលការកំឡាឲ្យចំរើនឡើង ។ ហេតុនេះហើយ បានជាសិស្សគ្រប់ៗគ្នា សុទ្ធតែចេះលេង យ៉ាងហោចណាស់នូវគ្រឿងភ្លេងមួយ ឬយ៉ាងតិចណាស់ ក៏ប្រព្រឹត្តនូវកីឡាណាមួយដែរ ។

បង្ខិតសាលាទៅរកការរស់នៅ ច្របល់ការសិក្សាជាមួយនឹងកិច្ចការបង្កើតផល ហើយ

និងសំរុះសំរួលទ្រឹស្តីជាមួយការប្រតិបត្តិ គឺជាខ្សែលំនាំមួយក្នុងចំណោមខ្សែលំនាំសំខាន់ៗ ដែលដឹកនាំការសិក្សានៅគូបា ។ ចំពោះរឿងនេះ ការបង្កើតសាលាតិកនិក និងសាលាតិកនិកជាន់ខ្ពស់ដែលជាសាលាបែបថ្មី គឺជាការសំខាន់ជាពិសេសនៅក្រោយពេលគេលុបបំបាត់សាលាមធ្យមសិក្សាជាន់ខ្ពស់ដែលគេយកចិត្តទុកដាក់តែទៅលើការសិក្សាទូទៅ ។

ព្រមគ្នានឹងចំណេះទូទៅយ៉ាងទូលាយ សិស្សនៃសាលាទាំងនេះ យ៉ាងតិចណាស់ ក៏បានចេះនូវតិកនិកណាមួយដែរ ។ តាមរយៈកម្មសិក្សា (stage) និងការបង្កើតផល សិស្សអាចបង្កើនចំណេះទាំងឡាយរបស់ខ្លួន ហើយស្ទួយចំណេះនេះដាក់ឲ្យដល់គំរិតដែលជីវិតទាមទារ ដោយយកវាមកពិនិត្យកែតំរូវក្នុងការប្រតិបត្តិ ដោយអនុវត្តធម៌ភាព និងទ្រឹស្តីក្នុងរបៀបផលិតកម្ម ហើយនឹងដោយរួមចំណែកដ៏ផ្ទាល់មួយក្នុងការបង្កើតសម្ភារៈប្រើប្រាស់ ។

ក្នុងរយៈពេល៤ឆ្នាំ គឺចាប់តាំងពីការដាក់ជាធរមាននូវប្រព័ន្ធសិក្សាខាងតិកនិកមក ក្នុងសាលាតិកនិក និងសាលាតិកនិកជាន់ខ្ពស់ទាំងឡាយ គេបានបង្កើតបានអ្នកជំនាញការ និងអ្នកជំនាញការថ្នាក់បន្ទាប់ជាច្រើនរយពាន់នាក់ plusieurs centaines de milliers ដែលសព្វថ្ងៃនេះ បានចូលរួមភាគទានយ៉ាងធំ ក្នុងការបដិវត្តន៍ខាងតិកនិក ខាងវប្បធម៌ និងខាងមនោគមន៍វិជ្ជារបស់ប្រទេស ។



## គេរៀនផង គេធ្វើការផង

សព្វថ្ងៃនេះ ជាង នឹងនយោជិតទាំងឡាយ អាចរៀនសូត្រដោយពុំចាំបាច់ចាក

រង្គផ្តិត នៅ វិទ្យាស្ថាន វេជ្ជវិទ្យា
ព្យុងយ៉ាង

បោលការងាររបស់ខ្លួនបាន នៅក្នុងសាលាតិកនិក (២ ឆ្នាំ) សាលាតិកនិកជាន់ខ្ពស់(២ឆ្នាំ) នឹងក្នុងវិជ្ជាស្ថាន (៤ ឆ្នាំ) ដែលមានដំណើរប្រព្រឹត្តទៅនៅក្នុងរោងចក្រសំខាន់ៗ ក្នុងសហ-គ្រាស ក្នុងអណ្ដូងរ៉ែ ក្នុងតំបន់សហករណ៍ នឹងតំបន់ចិញ្ចឹមសត្វ នៃប្រទេសទាំងមូល ។

គេទាំងឡាយមានលទ្ធភាពសន្ទឹកសន្ទាប់ណាស់ នឹងប្រើក្បាមៗ ក្នុងការងាររបស់គេ នូវទ្រឹស្ដីនឹងតិកនិក ដែលគេទើបនឹងបានរៀនបីក្នុងសាលា ។ ពេលម៉ោង នឹងបេក្ខខណ្ឌ ចាំបាច់ផ្សេងៗ សំរាប់ការសិក្សា ត្រូវបានរៀបចំសំរួលឥតខ្ចោះ សំរាប់សិស្សទាំងឡាយ ។ ចេញពីសាលាទាំងនេះមក គេសុទ្ធតែបានទទួលនូវការកំណត់ថ្នាក់ (quali-fication) នឹងបៀវត្ស ស្មើគ្នានឹងអ្នកមានសញ្ញាប័ត្រ នៃសាលារៀនពេលថ្ងៃ ឯទៀតៗ (écoles régulières) ។

សិស្សណាដែលរៀនតាមការឆ្លើយឆ្លង (par correspondance) ត្រូវធ្វើការសិក្សាខ្លួនឯង ដោយមានមេរៀន ដែលគេផ្ញើឲ្យជាជំនួយ ។ គេត្រូវមកអង្គុយក្នុងថ្នាក់រៀន មួយឆ្នាំតែពីរដង ក្នុងថេរវេលាមួយ (pendant un certain délai) ហើយអាចចូលទៅប្រឡងបាន ។ ក្នុងករណីនេះ គេនៅតែបើកប្រាក់បៀវត្សគេពេញដដែល ។ សោហ៊ុយទៅមករបស់គេ រដ្ឋជាអ្នករ៉ាប់រងទាំងអស់ ។ អ្នកប្រឡងជាប់សញ្ញាប័ត្រ ក៏បានទទួលបៀវត្ស ដូចគ្នានឹងអ្នកមានសញ្ញាប័ត្រនៃសាលារៀនពេលថ្ងៃដែរ ។

ដូចនេះ រោងចក្រ សហគ្រាស តំបន់សហករណ៍ តំបន់ចិញ្ចឹមសត្វទាំងឡាយ ៗលៗ គឺពុំគ្រាន់តែជាមូលដ្ឋានបង្កើតផលប៉ុណ្ណោះទេ ប៉ុន្តែក៏ជាមូលដ្ឋានបង្កើតអ្នកក្របខណ្ឌ (cadres) ថែមទៀតផង ។ ប្រព័ន្ធការសិក្សានៃប្រទេសនឹងបានរីកលូតលាស់ ហើយនឹងបានគុបតែងលំអរថែមទៀត ដើម្បីសំរុះសំរួលខ្លួនជាមួយការលូតលាស់នៃសង្គម នឹងការទាមទារនៃសង្គម នឹងការទាមទារនៃការពិតជាក់ស្ដែងតទៅ ។

# របៀបសិក្សា នៅប្រទេស
# កូរ៉េប្រជាធិបតេយ្យ ប្រជាមានិត





# វត្ថុបទ & ឯកសារ

## ប្រវត្តិវិទ្យា

### ប្រទេសអាល្លឺម៉ង់ ពីឆ្នាំ១៩១៩ ដល់ ១៩៣៩

រៀបរៀងដោយ ម៉ែ លង់

ប្រវត្តិនយោបាយប្រទេស អាល្លឺម៉ង់ ក្រោយពីសង្គ្រាមសាកលលោកលើកទី១មក ដល់នឹងមុនសង្គ្រាមសាកលលោកលើកទី ២ បានពើបប្រទះនឹងវិបត្តិជាច្រើន ដែលជាផលវិបាកនៃសង្គ្រាមលោកទី ១ ហើយដែលជាឱកាសមួយយ៉ាងអនុគ្រោះ ដល់ការស្ថាបនានូវរបបផ្តាច់ការលើប្រទេសអាល្លឺម៉ង់ ។ គេអាចនិយាយបានថា របបផ្តាច់ការនេះ ជាប្រតិកម្មរបស់មូលធននិយមនឹងកងទ័ព ប្រឆាំងនឹងអនាធិបតេយ្យ ដែលប្រទេសអាល្លឺម៉ង់បានស្គាល់ក្រោយចំបាំងសាកលលោក ។

វិបត្តិទាំងឡាយ ដែលប្រទេសអាល្លឺម៉ង់បានជួបកាត់មាន :

#### ក. វិបត្តិខាងសេដ្ឋកិច្ច នឹងហិរញ្ញវត្ថុ

សេដ្ឋកិច្ចអាល្លឺម៉ង់បានជួបកាត់នូវវិបត្តិមួយយ៉ាងធំ ក្រោយពីសង្គ្រាមភ្លាម ៗ យ៉ាងណាមិញ ប្រទេសអាល្លឺម៉ង់បានទទួលនូវការខូចខាតជាច្រើនក្នុងពេលចំបាំង ។ ក្រៅអំពីរោងចក្រ ឧស្សាហកម្មជាច្រើនដែលបានត្រូវអន្តរាយ ប្រទេសអាល្លឺម៉ង់ត្រូវផ្លាស់ប្តូរប្រែ

ឧស្សាហកម្មសឹករបស់ខ្លួន មកជាឧស្សាហកម្មស៊ីវិលវិញ ។ ក្នុងការដោះស្រាយបញ្ហានេះ ឧបសគ្គលេចឡើងជាច្រើន ដែលមានទិដ្ឋភាពស្មុគស្មាញមិនអាចនឹងដោះស្រាយបាន ភ្លាមៗឡើយ ។

ម្យ៉ាងទៀតប្រទេសអាល្លឺម៉ង់ ត្រូវសងដល់ប្រទេសខាងបក្សសម្ពន្ធ នូវប្រាក់កាសជាច្រើនកោដិ ព្រមទាំងប្រគល់ឲ្យពួកឈ្នះនូវមជ្ឈមណ្ឌលរ៉ែសំខាន់ៗទាំងឡាយ ដែលជាដង្ហើមនៃសេដ្ឋកិច្ចរបស់ខ្លួន ដូចជាអណ្តូងរ៉ែនៅដំបន់ រួរ (Rhur) ។

វិបត្តិសេដ្ឋកិច្ចធ្លាក់ចុះដុនដាបមួយកំរិតខ្លាំងថែមទៀត បន្ទាប់ពីមហាវិបត្តិសេដ្ឋកិច្ចសាកលលោកឆ្នាំ ១៩២៩ ដែលបានផ្ទុះជាដំបូងនៅសហរដ្ឋអាមេរិក ។ យ៉ាងណាមិញ ប្រទេសទាំងឡាយ ដូចជាចក្រភព អង់គ្លេស នឹងសហរដ្ឋ អាមេរិក ដែលធ្លាប់ឲ្យឥណទានដល់ប្រទេសអាល្លឺម៉ង់ខ្ចី ក៏បញ្ឈប់ពីត្រឹមពេលនោះមក ដោយប្រទេសខ្លួនកំពុងឆ្លងកាត់វិបត្តិឆ្នាំ ១៩២៩ នោះដែរ ។ មិនតែប៉ុណ្ណោះ ប្រទេសទាំងពីរខាងលើបង្ខំឲ្យរដ្ឋអាល្លឺម៉ង់សងប្រាក់ដែលខ្លួនខ្ចី មុនកំណត់ពេលទៀតផង ។ វិធានការទាំងនេះ បណ្តាលឲ្យប្រទេសអាល្លឺម៉ង់ខ្វះឥណទាន មិនអាចនាំទំនិញទៅបរទេសបានឡើយ ជាហេតុនាំឲ្យខ្វះរូបិយបណ្ណ ដើម្បីទិញវត្ថុធាតុដើមទាំងឡាយជាចាំបាច់សំរាប់ឧស្សាហកម្មរបស់ខ្លួន ។

វិបត្តិសេដ្ឋកិច្ចខាងលើបណ្តាលឲ្យមានវិបត្តិខាងហិរញ្ញវត្ថុ យ៉ាងខ្លាំងក្លាថែមទៀត ។ ដើម្បីទប់ទល់នឹងការត្រូវការរបស់រដ្ឋ គេបោះក្រដាសប្រាក់ជាច្រើនឥតគណនា ជាហេតុនាំឲ្យប្រាក់អាល្លឺម៉ង់បាត់បង់តម្លៃអស់ (inflation monétaire) ហើយគ្មានប្រទេសណាទទួលស្គាល់ឡើយ ។

ឧទាហរណ៍ :– ១ ម៉ាក (Mark) ជាមាសមានតម្លៃស្មើនឹង ៤.២៨០ ម៉ាកក្រដាសក្នុងខែមករា ១៩២៣ ឡើងដល់ ៨៤.០០០ ម៉ាកក្រដាសក្នុងខែកក្កដា, ១.១០០.០០០ ម៉ាកក្រដាសក្នុងខែសីហា, ២៣.០០០.០០០ ក្នុងខែកញ្ញា, ហើយឡើងដល់ ១០០ លាន ម៉ាកក្រដាសក្នុងខែធ្នូ ១៩២៣ ។

សំបុត្រមួយ ដែលក្នុងពេលធម្មតា គេបិទតែប្រិត្រឹម ១/១០ នៃប្រាក់ម៉ាក គេត្រូវបង់ដល់ទៅ ២ ឬ ៣ លាន ម៉ាក ។

បៀវត្សកម្មករ ឬភ្នាក់ងាររដ្ឋការ ត្រូវប្រែប្រួលមួយថ្ងៃ២ឬ៣ដង ឬក្នុងមួយម៉ោងម្ដងៗ ចាប់តាំងពីឆ្នាំ ១៩២៩ ផលិតផលឧស្សាហកម្មអាល្លឺម៉ង់ ត្រូវបានចុះថយជាលំដាប់ ។ ក្នុងឆ្នាំ ១៩៣២ ផលិតផលនេះ បានចុះថយជាងពាក់កណ្ដាល បើប្រៀបធៀបទៅនឹងផលិតផលឆ្នាំ ១៩២៩ ។

ស្ថានភាពសេដ្ឋកិច្ចក្នុងឆ្នាំ ១៩៣១ បានធ្លាក់ចុះមួយកំរិតយ៉ាងខ្លាំង ដែលគួរឲ្យថប់បារម្ភក្រៃលែង ។ វិបត្តិសេដ្ឋកិច្ចនឹងហិរញ្ញវត្ថុខាងលើ បានបង្កើតឲ្យមានវិបត្តិខាងសង្គមថែមទៀត ។

## ខ. វិបត្តិខាងសង្គម

ប្រាក់ចុះថ្លៃ ដូចជាក្រដាសកាសែត ទំនិញឡើងថ្លៃ សហគ្រាសឧស្សាហកម្ម ត្រូវបិទទ្វារ ផលិតផលខាងឧស្សាហកម្មលក់មិនចេញៗ ទាំងនេះ បណ្ដាលឲ្យកើតវិបត្តិខាងសង្គមមួយយ៉ាងធ្ងន់ធ្ងរក្រៃលែង ។ សហគ្រាសតូចតាចឬមធ្យម ត្រូវដួលរលំក្នុងពេលវិបត្តិឆ្នាំ ១៩២៩ ។ សហគ្រាសធំៗ នៅមានដំហររឹងប៉ឹង ហើយបាន "ទិញថោក" នូវសហគ្រាសឧស្សាហកម្មតូចៗ ឬមធ្យមទាំងនោះ មកជាសម្បត្តិរបស់ខ្លួន ដែលជាហេតុបណ្ដាលឲ្យនាយទុនធំៗប្រមូលមកកាន់កាប់ក្នុងកណ្ដាប់ដៃរបស់ខ្លួន នូវជីវភាពសេដ្ឋកិច្ចរបស់រដ្ឋទាំងមូល ។

ឯកម្មករគ្មានការធ្វើ មានចំនួនចេះតែកើនឡើងៗជាលំដាប់: កម្មករចំនួន១.៥០០.០០០ នាក់ គ្មានការធ្វើក្នុងឆ្នាំ ១៩២៩ ។ ចំនួននេះបានឡើងដល់ ៣.០០០.០០០ ក្នុងឆ្នាំ១៩៣០ និង ៧.០០០.០០០ នាក់ក្នុងឆ្នាំ ១៩៣១ ។ ទីក្រុងទាំងឡាយប្រែក្លាយទៅជាទីក្រុង "ងាប់" មានទិដ្ឋភាពក្រលំបាកគោកយ៉ាក ។ ចលាចល អសន្តិសុខ ការបះបោរមានពាសពេញ

លើផ្ទៃប្រទេស ។ ក្នុងដំបន់ខ្លះ ការអត់ឃ្លាន គ្មានអាហារបណ្ដាលឲ្យស្លាប់មនុស្សរាប់ពាន់នាក់ ។ ចំពោះស្ថានភាពប្រកបដោយគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរនេះ រដ្ឋាភិបាលពុំបានចាត់វិធានការអ្វីឲ្យច្បាស់លាស់ឡើយ ដែលជាហេតុបណ្ដាលឲ្យមានវិបត្តិខាងនយោបាយទៀត ។

## គ. វិបត្តិខាងនយោបាយ

គេអាចចែកវិស័យនយោបាយជាពីរសម័យ ។ សម័យទី១ គឺរបបគ្រប់គ្រង ដែលមានលក្ខណៈជាសេរីប្រជាធិបតេយ្យ (libéral, démocratique) ។ សម័យទី២ គឺរបបគ្រប់គ្រង ដែលមានលក្ខណៈជារបបផ្ដាច់ការ (dictature) ។

ក្នុងលក្ខណៈសម្បត្តិនេះ ហ៊ីត្លែរបានត្រូវគេចាត់ឲ្យទៅឃោសនាក្នុងកងទ័ព ដើម្បីអូសទាញពួកនេះឲ្យចេញពីលទ្ធិសង្គមនិយមលទ្ធិបុលសេវីសនិយម (Bolchévisme) ដែលកាន់តែរីកពលលូតលាស់យ៉ាងឆាប់រហ័ស ក្នុងចំណោមទាហាន ។ ក្រោយមក ហ៊ីត្លែរបានបង្កើតគណៈបក្សនយោបាយមួយមានឈ្មោះ "សង្គមជាតិនិយម" (National Socialiste) ។ ក្នុងប្រទេសអាល្លឺម៉ង់ ស្ថានភាពនយោបាយធ្លាក់ចុះក្នុងអនាធិបតេយ្យមួយពេញទី ។ រដ្ឋមន្ត្រីម្នាក់បាននិយាយថា : "ប្រទេសអាល្លឺម៉ង់ គឺដូចជាផ្ទះមួយ ដែលនៅក្នុងនោះមានសុទ្ធតែអ្នកឆ្កួត" ។

ការចលាចលខាងនយោបាយ បានផ្ទុះពេញលើផ្ទៃប្រទេស ។ ពួកប្រតិកិរិយាទាំងឡាយ (les réactionnaires) បានរួបរួមនឹងកងទ័ព ហើយប្រឆាំងនឹងគំរោងការកែទំរង់របស់រដ្ឋាភិបាល ប្រឆាំងនឹងរដ្ឋធម្មនុញ្ញ បានប្រើគ្រប់មធ្យោបាយដើម្បីកុំឲ្យរដ្ឋាភិបាលធ្វើការកើត ព្រមទាំងបានរៀបចំការប៉ុនប៉ងធ្វើឃាតលើឥស្សរជនទាំងឡាយណាដែលមាននិន្នាការប្រជាធិបតេយ្យ សេរីភាព ។ល។ ទៀតផង ។ តុល្យភាពខាងនយោបាយដែលលោកប្រធានាធិបតី ហ៊ិនដិងប៊ែរ (HINDENBERG) បានខំថែរក្សាតាំងពីដើមមកនោះ ក៏ត្រូវប្រេះឆារលំក្នុងពេលដែលលោកទទួលអនិច្ចកម្មទៅ ។

គណៈបក្សសង្គមជាតិនិយម ដែលមាន ហ៊ីត្លែរ ជាអ្នកដឹកនាំ បានឡើងកាន់កាប់កិច្ចការរដ្ឋតាំងពីពេលនោះមក ។ ជានាយករដ្ឋមន្ត្រី ក្នុងឆ្នាំ១៩៣៣ ហ៊ីត្លែរបានឈានទៅដល់កំពូលរដ្ឋតែម្នង ចាប់ពីឆ្នាំ ១៩៣៤មក (ជានាយករដ្ឋមន្ត្រីផង ជាប្រធានាធិបតីផង) ។

## ភ– កម្មវិធីនយោបាយរបស់គណៈបក្ស «សង្គមនិយម»

លុះបានឡើងកាន់អំណាចជាម្ចាស់រដ្ឋអាល្លឺម៉ង់ទាំងមូលពេញលក្ខណៈហើយ ហ៊ីត្លែរនឹងគណៈបក្សខ្លួន បានបញ្ចេញនូវកម្មវិធីនយោបាយមួយ ដែលមានចំណុចសំខាន់ៗ ដូចតទៅ :

ក– ធ្វើឲ្យសាសន៍ ជាតិ អាល្លឺម៉ង់មានឈាមបរិសុទ្ធ ហើយខ្លាំងពូកែ

ខ– បណ្តុះនូវសេចក្តីស្នេហាសង្គម នឹងប្រពៃណីរបស់ជនជាតិអាល្លឺម៉ង់

គ– ប្រមូលផ្តុំជនជាតិអាល្លឺម៉ង់ទាំងអស់ ឲ្យនៅជុំវិញតែអ្នកដឹកនាំម្នាក់ ដែលមានឋានៈជាមេ ជានាយក (Füher)

ឃ– លែកសន្ធិសញ្ញាក្រុង វែរសៃយ៍ (Versailles)ចោល ដើម្បីសំរេចនូវនយោបាយត្រួតត្រាពិភពលោកទាំងមូល ។

ការសំរេចនូវកម្មវិធីនយោបាយខាងលើ ពិសេសត្រង់ចំណុចទី ៤ នឹងបណ្តាលឲ្យមានហេតុ-ផលជាច្រើនចំពោះសន្តិភាពសាកលលោក ។

សម័យទី ១ :

ក្រោយពីចំបាំង ប្រទេសអាល្លឺម៉ង់បានរៀបចំបោះឆ្នោតជាសាកល ។ គណៈបក្សសេរីភាពដែលមានលោក អេប៊ែរ (Ebert) ជាអ្នកដឹកនាំ បានសំរេចជោគជ័យក្នុងការបោះឆ្នោតខាងលើ លើសគណៈបក្សណាៗទាំងអស់ ។

នៅថ្ងៃទី ៩ វិច្ឆិកា ១៩១៨ សាធារណរដ្ឋអាល្លឺម៉ង់ ត្រូវបានប្រកាសនាក្រុងប៊ែរឡាំង (Berlin) ហើយលោក អេប៊ែរ ត្រូវបានជ្រើសតាំងជាប្រធានាធិបតី ។

នៅថ្ងៃទី ១១ សីហា ១៩១៩ រដ្ឋធម្មនុញ្ញត្រូវបានប្រកាសឲ្យប្រើ ហើយដែលមានឈ្មោះថា "រដ្ឋធម្មនុញ្ញវៃម៉ារ" ដោយគេបានរៀបចំតាក់តែងរដ្ឋធម្មនុញ្ញនេះ នៅទីក្រុងវៃម៉ារ (Weimar) ។ រដ្ឋធម្មនុញ្ញបានសង្កត់លើអធិបតេយ្យភាពប្រជារាស្ត្រ ហើយ បានតែងឲ្យមានសភាពីរ គឺសភាតំណាងរាស្ត្រ (រ៉ៃស្តាក Reichstag) និងសភាតំណាងរដ្ឋ (ព្រឹទ្ធ-សភា ឬ រ៉ៃស្រាត Reichsrat) ។ រដ្ឋធម្មនុញ្ញ បានបើកសិទ្ធិសេរីភាពបោះឆ្នោតដល់ពលរដ្ឋទាំងពីរភេទចាប់ពីអាយុ ២០ ឆ្នាំឡើងទៅ ហើយបានគ្រោងទុកក្នុងកម្មវិធីរបស់ខ្លួន នូវការកែទម្រង់ខ្លះ ខាងវិស័យសេដ្ឋកិច្ច និងវិស័យសង្គមកិច្ច ។

ក្នុងឆ្នាំ ១៩២៥ លោកអេប៊ែរ បានទទួលអនិច្ចកម្ម ។ លោកហ៊ិនដិនប៊ែរ ( HIN-DENBERG) ដែលជាឧត្តមសេនីយចាស់ម្នាក់ ត្រូវបានជ្រើសតាំងជាប្រធានាធិបតី ។ សម័យនេះ ជាសម័យប្រកបដោយលក្ខណៈប្រជាធិបតេយ្យនិងសេរីភាព ប៉ុន្តែបញ្ហាសំ-ខាន់ៗដែលបានចោទយ៉ាងខ្លាំងពុំបានដោះស្រាយឡើយ ។ ផ្ទុយទៅវិញ វិបត្តិខាងសេដ្ឋ-កិច្ច ខាងសង្គម និងខាងនយោបាយ មានសភាពរឹតតែខ្លាំងឡើងៗជាលំដាប់ ។

### សម័យទី ២ :

ជាសម័យនៃរបបផ្តាច់ការរបស់លោក ហ៊ីត្លែរ ឬហ្វាស៊ីសនិយម ( Hitler, faxisme)

## ១- ជីវប្រវត្តិសង្ខេបរបស់ហ៊ីត្លែរ

ហ៊ីត្លែរ ជាជនសាមញ្ញម្នាក់ មានរបររកស៊ីជាជាងលាបផ្ទះ រស់នៅដោយលំបាកវេ-ទនា ខ្វះព្រឹក ខ្វះល្ងាច ក្នុងទីក្រុងម្យូនិច ( MUNICH ) ។ ដោយសង្គ្រាមលោកលើកទី ១ បានផ្ទុះឡើងភ្លាម គេមានចិត្តត្រេកអរខ្លាំងណាស់ ។ គេបានត្រូវរដ្ឋការហៅឲ្យចូលទៅបំរើក្នុងកងទ័ព ។ លុះពេលចប់ចំបាំង ហ៊ីត្លែរបានចាកចោលកងទ័ព ដោយមានឋានន្តរ-សក្តិជាពលបាលឯក (Caporal-chef) ។ គេជាវាគ្មិន (orateur) ម្នាក់មានសំដីពីរោះ ។

## ២– របបផ្ដាច់ការរបស់ហ៊ីត្លែរ

លុះបានឡើងកាន់អំណាចភ្លាម ហ៊ីត្លែរបានប្រើរបបផ្ដាច់ការ ហើយសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ក៏បានប្រែឈ្មោះជា រៃប្ស៊ទី ៣ (3e Reich) ។ គ្រប់អង្គការធំៗនៃរដ្ឋត្រូវហ៊ីត្លែរលុបចោលទាំងអស់ ដូចជាសភាតំណាងរាស្ត្រ សភាតំណាងរដ្ឋ ។ គ្រប់គណៈនយោបាយ ត្រូវបំបិទទ្វារទាំងអស់ លើកលែងតែគណៈបក្ស "សង្គមជាតិនិយម" របស់គេមួយប៉ុណ្ណោះ ។ បើពោលដោយសង្ខេបរបបផ្ដាច់ការរបស់ហ៊ីត្លែរ មានបាតុភាព ដូចតទៅ :

– ហ៊ីត្លែរ ជាអ្នកកាន់គ្រប់អំណាចរដ្ឋទាំងអស់តែម្នាក់ឯង

– គ្រប់គណៈបក្សដទៃទាំងអស់ទាំងប៉ុន្មាន ត្រូវវិនាសសាបសូន្យ

– សិទ្ធិសេរីភាពទាំងប៉ុន្មាន ត្រូវលុបចោលទាំងអស់

– ចំពោះជនជាតិយូឌ (Juif) ហ៊ីត្លែរទុកជាជនជាតិក្រៅច្បាប់ ពោលគឺនយោបាយសម្លាប់ចោលអស់នូវពូជពង្សជនជាតិយូឌនេះ ។

– ដូច្នេះ ខាងផ្ទៃក្នុងប្រទេស គឺជានយោបាយផ្ដាច់ការមួយ ដែលមានបាតុភាពនៅគ្រប់វិស័យទាំងអស់ ដែលបានដើរសាបព្រោះ តាមរយៈប៉ូលីសនយោបាយឈ្មោះ ហ្គេស្តាប៉ូ (GESTAPO) នូវការភិតភ័យទូទាំងប្រទេស ដែលបានចាប់បញ្ចូលពន្ធនាគារនូវគូសត្រូវខាងនយោបាយទាំងឡាយ ហើយដែលបានប្រើច្បាប់ព្រៃ (loi de la jungle) ក្នុងផ្ទៃរដ្ឋអាល្លឺម៉ង់ទាំងមូល ។

– ចំពោះនយោបាយក្រៅប្រទេសវិញ ហ៊ីត្លែរដែលមានចិត្តលោភលន់ឥតឧបមានោះ បានរិះរកគ្រប់មធ្យោបាយ ដើម្បីហែកសន្ធិសញ្ញាក្រុងវែរសៃយ៍ (Traité de Versailles) ចោល ពីព្រោះសន្ធិសញ្ញានេះជាឧបសគ្គដល់សេចក្ដីប៉ុនប៉ងធំត្រួតត្រាលោកលើយើងទាំងមូលរបស់ហ៊ីត្លែរ ។

ដើម្បីសំរេចនូវគោលបំណងខាងលើ ហ៊ីត្លែរបានស្ថាបនានូវឧស្សាហកម្មសឹកមួយ

យ៉ាងដាច់ខាត បានរៀបចំកងទ័ពមួយយ៉ាងខ្លាំងពូកែ ប្រកបដោយគ្រឿងសស្ត្រាវុធយុទ្ធភណ្ឌយ៉ាងទំនើបៗ នាយទុនទាំងឡាយនៅសហរដ្ឋអាមេរិក – ចក្រភពអង់គ្លេស នឹងនៅប្រទេស បារាំង បានជួយហ៊ីត្លែរយ៉ាងច្រើន ក្នុងការស្រោចស្រង់ស្ថាបនាសេដ្ឋកិច្ចប្រទេសអាល្លឺម៉ង់ ដោយគេទាំងអស់គ្នាសង្ឃឹមថានឹងយកហ៊ីត្លែរធ្វើជាឧបករណ៍នយោបាយមួយ សំរាប់ទប់ទល់នឹងសហភាពសូវៀត ។

ចំពោះហ៊ីត្លែរ គេបានអែបអបផិតស្និទ្ធនឹងបស្ចិមប្រទេស ដើម្បីជាកលល្បិចសំរាប់បំរើនយោបាយរបស់ប្រទេសគេផ្ទាល់ទៅវិញ ពោលគឺនយោបាយត្រួតត្រាពិភពលោកទាំងមូល មិនថាសហភាពសូវៀត ឬបស្ចិមប្រទេសឡើយ ។ តាមយោបល់របស់ហ៊ីត្លែរ ដើម្បីសំរេចនយោបាយខាងលើនេះ គេទុកសហភាពសូវៀតជាបច្ចាមិត្រលេខ ១ ។

លុះរដ្ឋហ៊ីត្លែរមានកម្លាំងពលំពេញលេញហើយ គេក៏ប្រើនយោបាយឈ្លានពាននយោបាយភគអាណានិគមតាំងពីពេលនោះមក ។ យ៉ាងណាមិញ ក្នុងខែកុម្ភៈ ឆ្នាំ១៩៣៨ ហ៊ីត្លែរបានយកប្រទេសអូទ្រីសមកភ្ជាប់នឹងរដ្ឋរបស់ខ្លួន (នយោបាយភ្ជាប់ប្រទេសអង់ស្លូស ANSCHLUSS) ។ ប៉ុន្មានខែក្រោយមក ហ៊ីត្លែរបានបែរទៅរកប្រទេសចេកូស្លូវ៉ាគី (Tchécoslovaquie) ម្ដងវិញ ។

ប្រទេសចេកូស្លូវ៉ាគីបានចងសម្ពន្ធមិត្រជាមួយនឹងសហភាពសូវៀត នឹងប្រទេស បារាំង ។ ការរំលោភលើប្រទេសនេះ នឹងបង្កើតនូវវិបត្តិជាមិនខាន ។ ការប៉ះទង្គិចក៏មុខតែនឹងកើតមានឡើងដែរ ។ តែក្នុងសន្និសីទមួយនាក្រុង មុយនិច (Munich ២៩–៣០ កញ្ញា ១៩៣៨ ) មហាអំណាចខាងលិច(អ៊ីតាលី–បារាំង–អង់គ្លេស)បានលក់ប្រទេស ឆែក (Tchèque) មួយភាគធំប៉ែកខាងលិចឲ្យហ៊ីត្លែរ ដោយពុំបានសួរដល់រដ្ឋាភិបាលសហភាពសូវៀត ហើយព្រមទាំងបានធ្វើលើខ្លួនប្រជារាស្ត្រ ឆែក ថែមទៀត ។

លោក បេណេស (BENES) ដែលជានាយករដ្ឋមន្ត្រី ឆែក ត្រូវបានអញ្ជើញទៅដែរ តែគេឲ្យលោកអង្គុយរង់ចាំសន្និសីទនេះក្នុងបន្ទប់មួយតែម្នាក់ឯងដើម្បីចាំទទួលយកលទ្ធផលនៃការពិភាក្សាខាងលើ ។

កិច្ចព្រមព្រៀងនាក្រុងម្យូនិច គឺជាកិច្ចសន្យាមួយរបស់មហាអំណាចចក្រភពអង់-គ្លេស -អ៊ីតាលី ពិសេសរបស់ បារាំង ដែលបានលក់ផលប្រយោជន៍ប្រជារាស្ត្រ ឆែក ទៅឲ្យហ៊ីត្លែរ ។

ការសមគំនិតនៃមហាអំណាចខាងលើ ដើម្បីបំពេញចិត្ត ហ៊ីត្លែរ មានគោលបំណងតែមួយ ពោលគឺសុំអង្វរហ៊ីត្លែរកុំឲ្យវាយលុកចូលក្នុងប្រទេសរបស់ខ្លួន ហើយឲ្យហ៊ីត្លែរបង្វែរមុខព្រួញរបស់ខ្លួនទៅរកសហភាពសូវៀតវិញ ។

ជាចុងក្រោយបង្អស់ នៅថ្ងៃទី១ កញ្ញា ១៩៣៩ លុះដឹងសេចក្ដីទន់ខ្សោយរបស់មហាអំណាចខាងលិច (បារាំង-អង់គ្លេស) ហើយ ហ៊ីត្លែរក៏បានបញ្ជាឲ្យកងទ័ពវាយលុកចូលប្រទេសប៉ូឡូញ ដែលជាដើមហេតុនៃសង្គ្រាមលោកលើកទី ២ ។

**CHEIKH ANTA DIOP**
Sénégal, historien et essayiste

◑ **Nations Nègres et culture** (Ed. P.A., prix 15 NF)
De ce document important, nous dirons simplement que c'est une tentative brillante de donner de nouvelles lettres de noblesse à l'Afrique humiliée par ses conférences faites devant des auditoires occidentaux Aimé Césaire, c'est le livre le plus audacieux qu'un Nègre ait écrit jusqu'ici et qui comptera, à n'en pas douter, dans le réveil de l'Afrique.

◑ **L'Unité culturelle de l'Afrique Noire** (Ed. P.A., prix : 12 NF)
L'auteur dégage pour ses lecteurs tous les traits culturels communs aux Africains. Un ouvrage qui doit contribuer à renforcer dans les Etats africains le sentiment des liens qui ont toujours uni les Africains d'un bout à l'autre du continent.

◑ **Fondements culturels techniques et industriels d'un futur Etat fédéral d'Afrique Noire** (Ed. P.A., prix : 4,50 NF)
L'auteur tire les conclusions pratiques de plusieurs années d'étude des problèmes africains. Une grande place est faite à l'unité linguistique et d'importants chapitres sont consacrés à l'unité politique, au fédéralisme ainsi qu'au recensement des sources énergétiques du continent africain.

# វិទ្យាសាស្ត្រធម្មជាតិ

ដោយ ម៉ម-ណៃ

សាស្ត្រាចារ្យវិទ្យាល័យ កំពង់ធំ-កំពង់ធំក្រុង

## គ្រុនសន្និ

គ្រុនសន្និគឺជាគ្រុនរលួយពោះវៀន ។ គ្រុននេះជាគ្រុនធ្ងន់ហើយកើតឡើងដោយមេរោគដែលចូលក្នុងខ្លួនយើងជាមួយនឹងចំណីអាហារដែលយើងបានបរិភោគ ។

### ក. លក្ខណរោគ

១– រយៈរោគមកទំ.– ក្នុងពេលនោះមេរោគបានចូលមកតាំងកន្លែងក្នុងកាយរបស់យើង ។ ព្រមជាមួយគ្នានោះវាបានបង្កើតកូនចៅយ៉ាងច្រើន ។ រយៈពេលនេះ មានកំណត់ពីពីរទៅដប់ប្រាំថ្ងៃ ។ ក្នុងពេលនោះ គេផ្ដើមហត់ហើយខ្សោយ គេបរិភោគចំណីអាហារលែងឆ្ងាញ់ គេឆ្អែតដេក ។ ទុកជាយ៉ាងនេះក៏ដោយ ក៏គេនៅតែធ្វើការងារបាន ។

២– ការចាប់ផ្ដើមនៃរោគ.– គេមិនអាចដឹងថា គេកើតជម្ងឺនុយច្បាស់បានទេ ព្រោះលក្ខណៈរោគមានមិនទាន់គ្រប់សព្វ ក្នុងពេលនោះគេមានសីតុណ្ហភាព៣៩–៤០°c។ ដំណើរហត់ ការមិនឆ្ងាញ់បាយ ការងងុយដេក ចេះតែកើតឡើង។ ។ គេឈឺក្បាល គេចុកដៃជើង ។ ឈាមហូរចេញពីច្រមុះថែមទៀតផង ។

៣– ភាពអាសន្ន.– លក្ខណរោគកើតឡើងគ្រប់គ្រាន់ក្នុងរយៈនេះ ។ សីតុណ្ហភាពចុះឡើង។ ។ អ្នកជម្ងឺមានកំដៅ ៣៩°c នៅពេលព្រឹក និង ៤០,៥°c នៅពេលល្ងាច ។ មុខគេបានឡើងក្រហម; ភ្នែកគេថ្លា ។ អណ្ដាតគេសក្រាស ហើយនឹងបបូរមាត់គេឡើងក្រមៅហើយស្ងួត ។ នៅពោះនឹងដើមទ្រូងគេ មានជាំតូចៗដ៏មានពណ៌ក្ហ

ឡាបលេចឡើង ៗ គេហើមពោះ ព្រោះពោះវៀនគេត្រូវធ្លុះធ្លាយរលាក ៗ ខាងក្រោយនេះជានិមិត្តនៃរូបរោគកាក ៗ គេបត់ជើងក្នុងមួយថ្ងៃៗជាងមួយសិបដង (ជាង ១០ ដង) ៗ តែដួនកាលគេត្រឡប់ទៅជាទល់អាចម៍ទៅវិញ ៗ ជាទីបំផុតគេមានភាពស្រឡាំងកាំង ៗ

៤– រយៈរោគអន់ថយ.– សីតុណ្ហភាពប្រែជាធម្មតា ៗ ភាពស្រឡាំងកាំងវិនាសបាត់ទៅ ៗ អាចម៍អន់រាគ ៗ ការឃ្លាញបាយមានឡើងវិញ ៗ ទាំងនេះប្រាប់ថានឹងជាហើយ តែគេត្រូវតមចំណីអាហារ ក្នុងពេលដែលគេទើបតែនឹងងើបអំពីឈឺ ៗ បើគេមិនតមដូចពោលនោះទេ ពោះវៀនតូចគេនឹងធ្លុះធ្លាយ ឈាមគេហូរចេញច្រើន បេះដូងគេមានដំណើរមិនស្រួល ៗ និមិត្តរូបខាងក្រោយនេះធ្វើឲ្យគេគ្មានសេចក្ដីសង្ឃឹមនឹងរស់នៅឡើយ ៗ

## ខ. បុព្វហេតុដើម

គ្រុនសន្ធំកើតឡើងដោយមេរោគម៉្យាង ៗ ក្នុងឆ្នាំ ១៨៨០ អាល្លឺម៉ង់ម្នាក់ឈ្មោះអេប៊ែរ្ត Eberth បានរកឃើញមេរោគគ្រុនរលួយពោះវៀននេះនៅក្នុងវក្កនឹងក្នុងកូនកណ្ដុររបស់អ្នកគ្រុនសន្ធំម្នាក់ ៗ មេរោគអេប៊ែរ្តជាដំបងមួយយ៉ាងតូចបំផុត ៗ វាមានប្រវែងពីពីរទៅបួនមីក្រុង (មួយមីក្រុង = $\frac{១}{១០០០}$ មម) ៗ ស្បែកមេរោគអេប៊ែរ្តមានរោម ដែលកំរើកបាន ៗ អាស្រ័យនូវរោមវាទាំងនោះ វាធ្វើដំណើរទៅមុខយ៉ាងងាយក្នុងវិលីននានា ៗ វាអាចទ្រាំរងា (–១១°c) នឹងភាពស្ងួតបានពីរខែ ៗ វាអាចរស់នៅដោយអត់ខ្យល់ ឬដោយមានខ្យល់ ៗ គេអាចចិញ្ចឹមមេរោគគ្រុនរលួយពោះវៀន នៅកន្ទ្វងចិញ្ចឹមដែលមានជាតិទឹកប្រមាត់ ៗ មេរោគដ៏សាហាវនេះចូលក្នុងពោះយើង តាមមាត់ជាមួយនឹងអាហារចំណីដែលយើងបរិភោគ ៗ វាតាំងលំនៅក្នុងពោះវៀនតូច ៗ នៅទីនោះ វាបង្កើតកូនចៅ រួចវាបញ្ចេញពិសពុលពីរមុខ ៗ កាលវានៅរស់វាបញ្ចេញពិសពុលម្យ៉ាង ដែលធ្វើឲ្យប្រព័ន្ធប្រសាទខូច ៗ ឯពិសពុលម្យ៉ាងទៀតកើតនៅពេលដែលខ្លួនវាងាប់ហើយរលួយ ៗ ពិសពុលប្រភេទនេះ ធ្វើឲ្យពោះវៀនតូចរលួយ និងធ្វើឲ្យកូនកណ្ដុរវិនាសអស់ ៗ

ដើមឡើយរោគគ្រុនសន្និនៅក្នុងពោះវៀនតូច ៗ វាចេញពីទីនោះ វាចូលទៅក្នុងឈាម ៗ ប៉ុន្មានថ្ងៃក្រោយមកវាចូលមកកន្លែងដើមវិញ ៗ ទីបំផុតវាត្រូវចេញមកក្រៅជាមួយនឹងអាចម៍–នោម ៗ

## គ. ការឆ្លង

គ្រុនសន្និអាចមានរបៀបឆ្លងពីរយ៉ាងគឺ ៖

### ១– ឆ្លងពីម្នាក់ទៅម្នាក់

បើយើងទៅប៉ះពាល់ ឬនៅស្និទ្ធស្នាលជាមួយនឹងអ្នកមានមេរោគអេបែរ្តហើយមិនឈឺ ឬជាមួយនឹងអ្នកគ្រុនសន្និ ឬជាមួយនឹងអ្នកទើបនឹងជា យើងនឹងកើតគ្រុនរលួយពោះវៀន បើមិនយូរក៏ឆាប់ ៗ

### ២– ឆ្លងពីអាហារបំណីមកមនុស្ស

ការឆ្លងនេះមានជាញឹកញយណាស់ ៗ អាហារដែលបណ្តាលនូវការឆ្លងនោះមាន ៖

● ទឹកផឹក គឺទឹកអណ្តូង, ទឹកព្រែក, ទឹកទន្លេ, និងទឹកម៉ាស៊ីនដែលមានបំពង់បែកៗ

● អាហារ គឺអាហារដែលប្រឡាក់ដី និងទឹកដែលមានមេរោគអេបែរ្ត ៗ អាហារទាំងនោះគឺបន្លែ, ផ្លែឈើស្រស់, ខ្យង ព្រមទាំងអាហារដែលរុយទំ ៗ រុយជាសត្វចង្រៃ ទំលេងលើអាចម៍របស់អ្នកគ្រុនសន្និ រួចនាំមេរោគអេបែរ្តទាំងឡាយមកទំលាក់ក្នុងអាហារបំណី ៗ ជាទីគួរឲ្យខ្លាចទៀត គឺអាហារបំណីស្ងោរដាំនិងធ្វើដោយអ្នកមានមេរោគអេបែរ្តប្រចាំកាយហើយៗមិនឈឺ ៗ

## ឃ. វិធីបង្ការរោគ

វិធីបង្ការរោគ គឺជាច្បាប់ដែលយើងត្រូវយកមកប្រតិបត្តិ ដើម្បីនឹងជៀសវាងឲ្យផុតរោគធ្ងន់ទាំងឡាយ ៗ ច្បាប់នេះមានពីរយ៉ាងគឺ ៖

### ១– ជៀសវាងការឆ្លង

● ត្រូវដាក់អ្នកគ្រុនរលួយពោះវៀនក្នុងបន្ទប់មួយតែម្នាក់ឯង នៅក្នុងគេហស្ថានរបស់

គេឲ្យនៅឯមន្ទីរពេទ្យ ។

● ត្រូវស្ងោរខោអាវអ្នកជម្ងឺ ។ ត្រូវចំហុយរបស់អ្វីដែលអ្នកជម្ងឺប្រើប្រាស់ ។ ត្រូវលាងបន្ទប់គេដោយទឹកក្រេហ្ស៊ីល (crésyl) ។ ត្រូវបាចកំបោរលើលាមកអ្នកជម្ងឺ ។

● ត្រូវពិនិត្យរកអ្នកមានរោគអេបែរ៍ហើយមិនឈឺ ។

● ត្រូវដាំទឹកឲ្យឆ្អិន ។

● ត្រូវគ្រប់ចំណីអាហារកុំឲ្យរុយទំ ។

● ត្រូវកុំបរិភោគផ្លែឈើនិងបន្លែស្រស់ ។

## ២– ការចាក់ថ្នាំបង្ការរោគ

គេយកមេអេបែរ៍ទៅសម្លាប់ដោយដុតឲ្យក្តៅចំនួន ៥៦°c ក្នុងមួយម៉ោង ឬគេយកមេរោគទៅដាក់ក្នុងអេតែរ (Ether) ។ ថ្នាំបង្ការនោះអាចការពារគ្រុនសន្ទំ និងគ្រុនសន្ទំ A-B ។ គេហៅថាថ្នាំបង្ការ TAB ។ ឯថ្នាំបង្ការម៉្យាងទៀត អាចការពារគ្រុនសន្ទំតាំងបីបែប និងរោគខាន់ស្លាក់-ជម្ងឺប្រេះ ។ ថ្នាំបង្ការក្រោយនេះមាននាម TABDT (តាបដេតេ) ។ គេចាក់ថ្នាំបង្ការរោគប្រភេទនេះចំនួនបីឬបួនម្តង ។ ម្តងដំបូងមាន ០,៧៥cc, ១cc និង១,៥cc (cc=សេសេ=សង់ទីគីប) ។ គេត្រូវចាក់ក្នុងចន្លោះពេលពី ១០ ទៅ ១៥ ថ្ងៃ ពីម្តងមួយទៅម្តងមួយទៀត ។ លើកលែងតែម្តងទី ៤ ដែលមានថ្នាំបង្ការតែ ១cc ហើយដែលត្រូវចាក់មួយឆ្នាំ ក្រោយម្តងទី ៣ ។ ម្តងទី ៤ នោះ សំរាប់ធ្វើឲ្យអានុភាពម៉្យាង ដែលមានហើយកាន់តែពូកែឡើង ។ អានុភាពម៉្យាងនោះ (immunité) អាចការពារគ្រុនសន្ទំបាន ៥ ឆ្នាំ ។

## ង. ការមើលជម្ងឺ

គេអាចប្រើ ៖

● ថ្នាំទីហ្វូមីស៊ីន

● សេរ៉ូមវ៉ាំងសង់ ( Sérum Vincent ) ។ សេរ៉ូមនេះអាចសម្លាប់មេរោគអេបែរ៍ និងបន្សាបពិសពុលរបស់មេរោគនោះ ។

# សិក្សារអក្សរខ្មែរ

ដោយនិស្សិតសាស្ត្រាចារ្យឆ្នាំទី២

## បញ្ហាចោទដោះស្រាយក្នុងរឿង "ក្រុងសុភមិត្រ"

*សំគាល់ : ក្នុងការសិក្សារឿងខ្មែរនិមួយៗ យើងត្រូវពិភាក្សាលើបញ្ហាអត្ថន័យ អត្ថរូបនឹងអត្ថរស ។ ក្នុងផ្នែកនិមួយៗមានបែកទៅជាច្រើនបែបសណ្ឋានទៀត តែក្នុងខណៈនេះ យើងខ្ញុំសូមលើកយកតែផ្នែកដ៏តូចមួយក្នុងបញ្ហាអត្ថន័យប៉ុណ្ណោះទេ ។*

**បញ្ហាទី១ :** ជុំវិញរឿងដណ្ដើមរាជ្យរបស់ក្រុងអសុភមិត្រ នឹងការលះបង់រាជសម្បត្តិរបស់ក្រុងសុភមិត្រ

ក) ជុំវិញរឿងដណ្ដើមរាជ្យរបស់ក្រុងអសុភមិត្រ

មូលហេតុ-- *លោភលន់អំណាច ដំណែងជាមហាឧបរាជហើយនៅមិនទាន់ស្កប់ស្កល់ទៀត ហើយខ្វល់ថាព្រះរៀមសោយរាជ្យយូរពេកឥតគិតដល់ព្រះអនុជ*

*ទំព័រ ១១ ខ្សែ I "ថាព្រះរៀមរាជចក្រី ស្ដេចពុំប្រណី ឲ្យរាជសម្បត្តិរដ្ឋ ស្ដែងស្ដេចពុំពិចារណា សោយសុខសក្កា ឥសូរសម្បត្តិយូរលង់" ។*

*– ប្រណែនដោយខ្លាចរាជ្យ ធ្លាក់ទៅរាជបុត្រព្រះរៀម*

*– ខ្លាចពាក្យដំនៀលថាស្ដេចឥតចេស្ដា*

*ទំព័រ ១១ I : "ដំណាដំនៀលនិន្ទា ក្សត្រឥតចេស្ដា នឹងជាប្រយោជន៍គលអ្វី ។*

*ពុំបានគ្រប់គ្រងបុរី បុរាណរេណី តំណតំណាងបិតា ។"*

*– មានការគោរសមគំនិតជាមួយពួកនាហ្មឺនមន្ត្រី គឺមានពួកក្នុងឲ្យដៃ*

*ទំព័រ ១១ I : "រីរាជសម្បត្តិរដ្ឋ គួរតែក្សត្រា គ្រប់គ្រងរក្សាស្ត្រារាជរេណី ។*

ទើបត្រូវក្រិត្យក្រមសេចក្ដី ដូចពជសវនីយ៍ ពុំចេះទ្រង់ព្រះចិន្ដា ។
ចំណោរលង់យូរហើយណា រឹពដរដ្ឋា សមបានកុមារពីរពង្ស ។ ”

ការអនុវត្តិ : មធ្យោបាយប្រើគឺ រដ្ឋប្រហារដោយអាវុធ ។ ក្រោយពីការស្រុះស្រួលមូលមាត់ហើយ ព្រះអនុជក៏បង្គាប់ឲ្យសេនាមាត្យរៀបពលទ័ពប្រដាប់ដោយអាវុធយុទ្ធភណ្ឌទៅឡោមព័ទ្ធព្រះដំណាក់ព្រះរៀមតែម្ដង ។

ការពិភាក្សា : ១) លេចចេញមូលហេតុមួយទៀត គឺថាមកពីកម្មពីអតីត(១)របស់ក្រុងសុគមិត្រ ។ នេះជាមតិមួយដែរ ព្រោះកវីក៏បានបញ្ជាក់ថា មកតែពីកម្មនេះដែរ ។

— ក្រោយការពិភាក្សា យើងយល់ឃើញថា បើដាក់តែកម្មពីអតីតមួយមិនគ្រប់គ្រាន់ទេ កវីក៏បានបញ្ជាក់ថាមកពីមូលហេតុច្រើនដែរ ។ ម្យ៉ាងទៀត កម្មក្នុងទីនេះ ពុំមែនជាកត្តាធំទេ ។ កត្តានេះនឹងនាំឲ្យតែយើងលែងមានជំនឿលើខ្លួនឯងប៉ុណ្ណោះ ។ ព្រះពុទ្ធទ្រង់ទូន្មានថា : “អត្តាហិ អត្តនោ នាថោ” (ខ្លួនទីពឹងខ្លួន) ។ យើងមិនត្រូវបេះតែបណ្ដោយទៅតាមកម្ម ពៀរវេរ ឬ ព្រេងវាសនានោះទេ ។ លើសពីនេះទៀត វានឹងនាំឲ្យយើងលែងទទួលខុសត្រូវចំពោះខ្លួនយើង លែងចៀសវាងអំពើអាក្រក់ ។

ក្នុងទីនេះ បើតាមជំនឿខាងលើ ក្រុងអសុគមិត្រមិនត្រូវទទួលខុសត្រូវចំពោះអំពើក្បត់ផែនដី ក្បត់ព្រះរាជានេះទេ ទោះព្រះអង្គ(អសុគមិត្រ)ធ្វើខុសយ៉ាងណាក្ដី ព្រោះព្រះអង្គគ្រាន់តែជាកត្តាធ្វើឲ្យក្រុងសុគមិត្រទ្រង់ទទួលកម្មតែប៉ុណ្ណោះ ។ ប៉ុន្ដែបើនិយាយដូច្នេះ មនុស្សនឹងប្រែជាឥតមានខ្លឹមសារសោះហើយ ។

យើងសូមលើកឧទាហរណ៍ជាក់ស្ដែងមួយ : សម្ដេចឪ ដែលត្រូវអាក្បត់ សម សារី សឺង ង៉ុក-ថាញ់ វាជេរត្មះតិះដៀលព្រះអង្គរាល់ថ្ងៃ តើមកពីអ្វី? — មកពីកម្មរបស់ព្រះអង្គពីអតីតឬ? បើដូច្នោះមែន មិនអាថាញ់-សារី វារួចពីការទទួលខុសត្រូវចំពោះអំពើក្បត់របស់វាទៅហើយ ។ យើងយល់ថាពុំមែនដូច្នោះទេ ពុំមែនមកពីកម្មព្រះអង្គពីអតីតទេ គឺមកតែ

(១) សូមមើលបញ្ហាទី ៤

ពីព្រះអង្គទ្រង់រកសេចក្ដីចំរើនជូនជាតិ ដែលមិនបានជាទីពេញចិត្តរបស់ពួកអាក្បត់នេះឯងៗ កត្តានៅត្រង់នេះទេ នៅត្រង់ថាអាក្បត់ក៏ឈ្នានីស ក៏ចង់ពន្លិចជាតិ ហើយក៏មិនបានដូចបំណងក៏ ព្រោះតែសម្ដេចឪនេះឯង ៗ

២) ក្រុងអសុកមិត្រ ព្រះអង្គពុំគួរណាចង់ដណ្ដើមរាជ្យសោះ ព្រោះដំណែងព្រះអង្គក៏ពុំមែនតូចដែរ ព្រះអង្គជាអនុជហើយមានយសសក្ដិជាឧបរាជ បន្ទាប់ពីស្ដេចព្រះវៀមមកហើយ ពុំគួរព្រះអង្គលោភលន់សោះ ៗ ធ្វើយ៉ាងនេះជាហេតុនាំឲ្យតែគេនិន្ទាថា ព្រះអង្គឈ្មោះតែបងប្អូនឯង ដណ្ដើមរាជ្យដែលជាហេតុនាំឲ្យមានផលវិបាកច្រើន ៗ ព្រះអង្គទ្រង់គិតខ្លាចក្រែងគេនិន្ទាថាព្រះអង្គឥតបេស្ដា ៗ តើបេស្ដានៅត្រង់ណា? បើប្រសិនជាព្រះអង្គរួមសាមគ្គីស្រុះស្រួលជាមួយព្រះវៀម ជួយកិច្ចការព្រះវៀមដោយស្មោះស្ម័គ្រ ជួយគិតគូរផលប្រយោជន៍នគរ ផលប្រយោជន៍ប្រជានុរាស្ត្រ នោះច្បាស់ជានឹងមានកិត្តិនាមល្បីរន្ទឺឮសុះសាយចំពោះព្រះអង្គផង ចំពោះព្រះរាជវង្សផង នឹងចំពោះព្រះនគរផង ៗ

ព្រឹត្តិការណ៍នេះអាចបញ្ជាក់ឲ្យឃើញថា មនុស្សលោភលន់គិតតែពីការសប្បាយក្នុងទ្រព្យសម្បត្តិ យសសក្ដិបែបអសុកមិត្រជាមនុស្សវង្វេងឥតដឹងខុស ត្រូវ អាក្រក់ ល្អ បន្តិចសោះ ៗ មនុស្សប្រភេទនេះគ្មានស្រឡាញ់នរណាក្រៅពីខ្លួនឯងឡើយ ៗ ដូច្នេះគេឥតញញើតនឹងប្រព្រឹត្តអំពើក្បត់គ្រួសារ ក្បត់ជាតិរបស់គេទេ ៗ

៣) ម្យ៉ាងទៀតបើគ្មានការគាំទ្រយ៉ាងកក់ក្ដៅពីនាម៉ឺនមុខមន្ត្រីទេ ពិតជាផែនការក្បត់របស់អសុកមិត្រពុំអាចសំរេចបានឡើយ ៗ ដូច្នេះពួកនាម៉ឺនទាំងនេះក៏ជាសការៈអាក្រក់គិតតែប្រយោជន៍ផ្ទាល់ខ្លួនឥតនឹកនាដល់ប្រយោជន៍ជាតិបន្តិចសោះ ៗ ពួកនេះច្បាស់ជាសង្ឃឹមថា មុខជានឹងបានទទួលរង្វាន់ពីក្រុងអសុកមិត្រមិនខានឡើយ ៗ

៤) បើយើងក្រឡេកមើលសកម្មភាពរបស់ពួករេហ៍ពលសេនាយោធារបស់អសុកមិត្រវិញ យើងអាចសង្កេតឃើញថា ពួកនេះបណ្ដោយឲ្យគេញាក់បានតាមចិត្ត ៗ ពួកទាំង

នេះហ៊ានយកជីវិតទៅប្តូរក្នុងការប្រឆាំងនឹងប្រយោជន៍ជាតិ ប្រយោជន៍គ្រួសារឯង ដើម្បីបំរើផលប្រយោជន៍មនុស្សមួយក្រុម ៗ ពួកពលសេនាយោធា ដែលជាចន្ទល់ការពារប្រទេសជាតិពិតប្រាកដ ចេះពិចារណារកហេតុផល ចេះស្រឡាញ់ជាតិ ស្រឡាញ់ប្រជារាស្ត្រ ហើយមិនក្លាយខ្លួនទៅជាឧបករណ៍បំរើផលប្រយោជន៍មនុស្សអាក្រក់បែបអសុភមិត្រទាំងងងិតងងល់ទេ ៗ

### ខ) ជុំវិញការលះបង់រាជសម្បត្តិរបស់ក្រុងសុភមិត្រ

លុះទ្រង់ដឹងដំណឹងពីផែនការក្បត់ក្លាម ក្រុងសុភមិត្រ ព្រះអង្គទ្រង់លះបង់រាជសម្បត្តិ ហើយទ្រង់នាំមហេសីនឹងបុត្ររត់ភៀសព្រះអង្គ ៗ

មូលហេតុដែលបណ្តាលឲ្យព្រះអង្គទ្រង់សំរេចយ៉ាងនេះ ៖

— មកពីទ្រង់កាន់ខន្តី

— មកពីទ្រង់យល់ថា របស់ទាំងអស់ឥតរូប ឥតខ្លឹមសារ ឥតទៀងទាត់

● ទំព័រ ១៣I "ស្តេចគិតសង្វេគ អនិច្ចា រូបំ អនត្តា ឥតខ្លឹមឥតសារសូន្យសោះ ៗ
សង្សារបណ្តាលទោសស្មោះ តែត្រើយឥតកោះ ពំនាក់ពំនឹងរូបបាន ៗ"

— មកពីទ្រង់មិនចង់ឲ្យកើតកង្វល់អន្តរាយដល់រាស្ត្រប្រជា

● ទំព័រ ១៣I "យង់យល់តែសីលនឹងទាន ទៀងទើបនាំប្រាណ រួចចេញពីចតុរាបាយ ៗ"
"បើយើងតតាំង កងទ័ពចេញច្បាំង ឲ្យយល់ឫទ្ធិ ក្រែងកើតកង្វល់
អំពល់សេចក្តី អាសូរប្រណី រាស្ត្ររដ្ឋទាំងឡាយ ៗ នឹងកើតផ្សាក្តៅ
ព្រាត់ប្រាស់កូនចៅ ហិនហោចខ្ចាត់ខ្ចាយ ស្លុតស្លាប់សូន្យសោះ ហេតុនោះ
អញណាយ មិនឲ្យអន្តរាយ ដល់ជាតិឡើយហោង ៗ"

— មកពីព្រះអង្គទ្រង់ខ្លាចមរណភាព ៗ

— មកពីកម្មពីអតីត(១) ៗ

---

(១) កំណត់ពិភាក្សាដូចខាងលើ ។

ការពិភាក្សា : ១– ពេលដឹងដំណឹងក្ងាម ព្រះរាមទ្រង់ក្រោធជាខ្លាំង ។

● ទំព័រ ១៣I "ក្ដៅថ្ងើម ដង្ហើមផ្សាយផ្សា ស្ទើរបែកទ្រូង ព្រះនេត្រប្រាលដូចអគ្គី ។" តែក្រោយមកព្រះអង្គទ្រង់សង្កត់បាន ហើយទ្រង់គិតជញ្ជឹងពិចារណាម្ដងវិញ ។

ត្រង់នេះគួរឲ្យសរសើរព្រះអង្គណាស់ ព្រោះព្រះអង្គអាចយកខន្តីមកទប់ទាន់ពេលវេលា ។ ហើយម្យ៉ាងទៀត ព្រះអង្គត្រូវតែទុកពេលគិតជញ្ជឹងដូច្នេះឯង ព្រោះអីបើព្រះអង្គទ្រង់ពុំបានពិចារណារកសខ្មៅ ព្រះវាចាព្រះអង្គនឹងនាំឲ្យមានផលវិបាកអាក្រក់ច្រើន ។

ខ. នៅពេលដែលនាយសំពៅក្រាបទូលពីរឿងថាមាន "សហាយស្មន់" ព្រះអង្គទ្រង់ក្រេវក្រោធយកទោសរាជបុត្រទាំងពីរអង្គ ដែលគួរឲ្យស្ដាយជាពន់ពេក ។

២– ការដែលព្រះអង្គទ្រង់យល់ថា រាជសម្បត្តិឥតរូប ឥតខ្លឹមសារ ជាព្រះគតិល្អណាស់ ។ ព្រះអង្គទ្រង់មិនចង់ឲ្យជាប់ជំពាក់តែនឹងរឿងរាជសម្បត្តិ ដែលជាហេតុបណ្ដាលឲ្យមានផលវិបាកមិនល្អ ។

លុះក្រោយមកព្រះអង្គទ្រង់ទទួលរាជសម្បត្តិនគរមួយផ្សេងទៀត ។ តែគួរពិចារណាដែរថា រាជសម្បត្តិនៅនគរតក្កសិលា គេលើកថ្វាយព្រះអង្គដោយស្មោះ ។

៣– បញ្ហាដែលថាព្រះអង្គទ្រង់មិនចង់ឲ្យកើតកង្វល់ អន្តរាយដល់ប្រជារាស្ត្រអាចបញ្ជាក់បានដូចខាងក្រោមនេះ ៖

ក) ទស្សនៈនេះត្រឹមត្រូវ: – ដោយមិនត្រូវឲ្យអន្តរាយដល់ជីវិតរាស្ត្រដោយសារតែរាជបល្ល័ង្ក ដោយសារតែរៀមនឹងអនុជ – ដោយមិនត្រូវឲ្យមានវិវាទរវាងរៀមនឹងអនុជរួមឧទរ – ដោយចង់រក្សាកិត្តិយសគ្រួសារ – ដោយនិយមសន្តិភាព

ខ) ទស្សនៈនេះមិនត្រឹមត្រូវ: – គំរូអាក្រក់ បណ្ដាលឲ្យក្រុងអសុភមិត្រឡើងសោយរាជ – ទ្រង់បោះបង់ចោលរាស្ត្រ លែងនឹកនាដល់សោះ នាំឲ្យរាស្ត្ររងារ មាន

ទុក្ខព្រួយវិញ – កំសាកនិយម

គ) ទស្សនៈរួម : ពេលជាបន្ទាន់នោះ ដើម្បីចៀសវាងសង្គ្រាមបង្ហូរឈាម ព្រះអង្គត្រូវតែយាងគេចចេញដូច្នេះឯង ប៉ុន្តែគួរតែព្រះអង្គគ្រាន់តែដកឃ្លាយកនាទីឲ្យបានស្រួលសិន ធ្វើម្តេចបើព្រះអង្គបានជាធ្លោយក្តាប់នាហ្មឺនមន្ត្រីអនុជព្រះអង្គ នឹងពលទាហានពុំជាប់ហើយ (តែក៏ជាមេរៀនមួយដែរ) ពេលនោះគួរព្រះអង្គទ្រង់ស៊ើបក្នុងចំណោមប្រជារាស្ត្រ ដែលស្នេហាយុត្តិធម៌ ស្នេហាព្រះអង្គ (ព្រោះប្រជារាស្ត្រស្រឡាញ់ព្រះអង្គច្រើនណាស់(១)) ហើយដឹកនាំអ្នកទាំងនោះតស៊ូរកយុត្តិធម៌ ដល់ជាតិ ដល់ព្រះអង្គផ្ទាល់នឹងដល់ប្រជារាស្ត្រផង ។ តែពុំគួរព្រះអង្គរត់ចោលប្រជារាស្ត្រឲ្យរងវេទនាដូច្នេះទេ ដែលផ្ទុយនឹងព្រះភារៈនាទីព្រះអង្គជាមគ្គុទ្ទេសក៍ជាតិ ។ ទ្រង់ធ្វើដូច្នេះ នាំឲ្យប្រជានុរាស្ត្រយល់ថា ព្រះអង្គកំសាកទៅវិញ ។

៤– ព្រះអង្គទ្រង់យល់ថា ព្រះអង្គនឹងទ្រង់យាងចេញទៅរកសីល ។ នេះជាការល្អណាស់ ។ តែក្នុងរឿងគ្មានបានបញ្ជាក់ថា ព្រះអង្គទ្រង់សាងសីលសោះ មានតែព្រះអង្គសោយសោក រួចសោយរាជ្យនគរមួយទៀតតែប៉ុណ្ណោះ ។

៥– កត្តាចុងក្រោយទៀត គឺព្រះអង្គទ្រង់ខ្លាចស្លាប់នេះឯង ។

● ទំព័រ ១៦I "ចូលប្អូនមាសអត់ តាមក្តីកំសត់ ខំចរយាត្រា
ក្រែងអស់មនុស្សផង យល់បងហើយវា ទៅប្រាប់អនុជា នឹងតាមមកនៃ ។
ក្រែងគេចោមចាប់ យកទៅសម្លាប់ ជីវិតក្សណក្ស័យ សេនាគេស្រាប់
ប្រដាប់ច្រើនក្រៃ ធ្វើសង្គ្រាមជ័យ យករាជសម្បត្តិ ។
ប្អូនអើយយើងក្រ យើងរួសរត់រក ពឹងព្នងព្រៃស្ងាត់...." ។

(១) សូមមើលបញ្ហាបន្ទាប់

បញ្ហាទី២ : ក) បើក្រុងសុភមិត្រជាក្សត្រល្អវិសេសមែន ម្ដេចឡើយក៏គ្មានសេនាមាត្យ ឬរាស្ត្រណាមួយទៅតាមបំរើរក្សាព្រះអង្គ ?

– សេនាមាត្យ ស្នំ កំលោះមានសពោ្វតនាចំពោះព្រះអង្គដែរ ។ គេនាំគ្នាសោកសង្រេង;

● ទំព័រ ២៦ I "ស្រីស្នំស្រីគ្គារ សឹងសោកកូបាល ទ្រហឹងគោឡោ អាណាគអាណិត គន់គិតពង្សពោ- ធិសត្វសេដ្ឋា ចេញចាកបុរី ។"

– តែការស្រឡាញ់ អាណិតរបស់ស្នំ អាមាត្យ កំលោះស្ថិតនៅតែត្រឹមសពោ្វតនាប៉ុណ្ណោះ ពុំលុះដល់សកម្មភាពជាក់ស្ដែងឡើយ គឺខ្វះការគេស្ម័គ្រចំពោះមហាក្សត្ររបស់ខ្លួនៗ ឯប្រជារាស្ត្រទូទៅវិញ មានលំនាំដូចសេនាមាត្យដែរ គឺមានការស្រឡាញ់ ស្នេហាព្រះមហាក្សត្រដែរ;

● ទំព័រ ៤ I "រាជវង្សអង្គសេនា រាស្ត្រប្រជាសុខសប្បាយ ដើរលេងរាំរៀងរាយ សព្វគ្រប់ស្មេងកេសុខក្សេមក្សាន្ត នីរទោសនីរទុក្ខា នីរភយាមកបៀតបាន..."

● ទំព័រ ៨ I "អស់រាស្ត្រផងទាំងឡាយ សឹងសរសើរព្រះបារមី ..."

– តែសេចក្ដីស្នេហានេះមិនបានស៊ីជំរៅ មិនបានចូលជាសាច់ជាឈាមផងខ្លួន ។ ហេតុនេះហើយបានជាក្រុងសុភមិត្រគ្មានទុកចិត្តនរណាសោះ នៅពេលមានអាសន្នៗ

● ទំព័រ ១៦ I "ប្ដូរប្អូនមាសអត់ តាមក្ដីកំសត់ ទំបរយាត្រា ក្រែងអស់មនុស្សផង យល់ចង់ហើយរា ទៅប្រាប់អនុជា នឹងតាមមកនៃ ។ ក្រែងគេចោមចាប់ យកទៅសម្លាប់ ជីវិតក្សិណក្ស័យ សេនាគេស្រាប់ ប្រជាប់ច្រើនក្រៃ ផ្ដើសង្គ្រាមជ័យ យករាជសម្បត្តិ ........ នៅនិត្យដូចសត្វ សោះគេយង់យល់ ។"

ឃ្លានេះបញ្ជាក់ឲ្យឃើញថា ព្រះអង្គខ្លាចមហាជនណាស់ ។ ព្រះអង្គទំលួងលោមមហេសី កុំឲ្យសោកសង្រេងអី កុំឲ្យឮដល់គេ ឲ្យរស់នៅក្នុងព្រៃដូចជាសត្វសោះទីងគេមើលយល់ ។

ការពិភាក្សា: ១– ត្រង់នេះហាក់ដូចជាមានទំនាស់ នឹងមតិពីខាងលើ ដែលថែងថា ប្រជារាស្ត្រស្រឡាញ់ព្រះអង្គច្រើន ៗ បើពិនិត្យមើលឲ្យជ្រៅ មិនជាទំនាស់ទេ ព្រោះប្រជាពលរដ្ឋស្រឡាញ់ព្រះអង្គពិតហើយ តែគេទាំងឡាយមើលមិនឃើញផ្លូវ ឬវិធីណាជួយស្រោចស្រង់ព្រះមហាក្សត្រ ហើយឲ្យបសគ្គម៉្យាងទៀត ស្ថិតត្រង់គេខ្វាច ខ្វះការក្លាហាន ពុះពារតស៊ូ មកពីគេមិនទាន់ជឿកម្លាំងខ្លួនឯង មិនទាន់ជឿលើកម្លាំងសាមគ្គី ៗ ហេតុនេះលុះត្រាតែព្រះអង្គព្យាយាម អប់រំពន្យល់គេ ហើយដឹកនាំគេតស៊ូ ទើបបានសំរេចផលៗ

២– ទំព័រ៣I "ស្ដេចថ្កើងព្រះស័ក្ដា ជាទឡ្ហារិកពេកក្រៃ

អស់ក្សត្រផងដទៃ ទាំងរយមួយមកវន្ទា ៗ

ព្រះកេរ្ដិ៍ខ្ពស់ចិញ្ចែង នរអ្នកស្ញែងខ្លាចបេស្ដា

ថ្កើងបុណ្យទ្រង់ពលា ជាអនន្តពន់ប្រមាណ ៗ"

ទីងឃ្លាជាច្រើនទៀតបានបញ្ជាក់ថា ក្រុងសុភមិត្រហាក់ដូចជាមានបុទ្ធីបេស្ដាខ្លាំងពូកែណាស់ ពុំគួរមកខ្លាចអីខ្លាចយ៉ាងនេះសោះ ៗ ត្រង់នេះយើងមានយោបល់ថា ព្រះអង្គទីងពូកែបានក៏ដោយសារការរួមសាមគ្គីរវាងព្រះអង្គ ព្រះអនុជ នាហ្មឺន មន្ត្រី រាស្ត្រប្រជាគ្រប់ជាន់ថ្នាក់ ៗ តែបើតែមួយព្រះអង្គឯង ឬតែបែកបាក់សាមគ្គី ច្បាស់ជាព្រះអង្គពុំអាចបង្ក្រាបសត្រូវបានឡើយ ៗ

១) ក្រុងសុភមិត្រទ្រង់ពុំបង់យកមហេសីនឹងរាជបុត្រទៅតាមជាមួយ ត្រង់នេះពិតជាលក្ខណៈវីរភាពរបស់ព្រះអង្គឬទេ? ពិតជាលក្ខណៈពោធិសត្វបេញសាងបារមីឬទេ?

– ព្រះអង្គទ្រង់យល់ថា កុំឲ្យមហេសីនឹងកូនបុត្រលំបាកវេទនា ដោយដើរព្រៃ ៗ ចុះបើនៅក្នុងវាំង តើព្រះអង្គទ្រង់ហ៊ានធានាថា មហេសីនឹងកូនបុត្រចៀសរួចពីការលំបាក

ឬទារុណកម្មឬទេ? ដូច្នេះពុំមែនជាលក្ខណៈវីរភាពទេ ព្រោះថាលុះណាតែហ៊ានតស៊ូ គឺពុំមែនកំសាកទេ ។ នេះព្រះអង្គទ្រង់ចង់យករូបតែមួយព្រះអង្គឯង ។

– ព្រះអង្គទ្រង់យល់ថាចង់ចេញសាងបារមី ។ បើចង់ចេញសាងបារមីក៏ពុំត្រូវចោលមហេសីនិងរាជបុត្រឲ្យរងទុក្ខវេទនាដែរ ។ ព្រះពុទ្ធអង្គ ពេលព្រះអង្គយាងចេញសាងព្រះផ្នួស ព្រះមហេសីនាមពិម្ពាទ្រង់មានការធានាអះអាងសន្តិសុខស្រួលបួល ។ ឯព្រះស្រីវេស្សន្តរ ដែលព្រះអង្គទ្រង់ពុំចង់យកមហេសីទៅតាមក៏ដូច្នោះដែរ ។ ដូច្នេះពុំមែនជាលក្ខណៈពោធិសត្វចេញសាងបារមីទេ ។ ម្យ៉ាងទៀត ព្រះអង្គទ្រង់ពុំទាំងបានសាងបារមីផង ។ បើនៅពេលមុនយាងចេញ នឹងពេលសោយរាជ្យនគរតក្កសិលានោះ ព្រះអង្គទ្រង់ធ្វើសីលដាក់ទានមែន... ។

ការពិភាក្សា : អាចមានមតិមួយទៀតថា បើព្រះនាងគង់នៅនគរ ក៏អាចធានាអះអាងដល់សន្តិសុខបានដែរ ព្រោះព្រះនាងជាកន្យែសារពេជ ។ កស្តុតាងនាយសំពៅពុំអាចណានឹងចូលជិតបានឡើយ ។ មតិនេះសមម្យ៉ាងហើយ តែថា តើព្រះនាងទ្រង់សប្បាយចិត្តឬទេ? តើព្រះអង្គទ្រង់ពេញចិត្តនឹងទុកឲ្យមហេសីរងទុក្ខវេទនាដូច្នេះឬ? បើថាជាមួយនាយសំពៅចុះ ធ្វើម្តេចព្រាត់ប្រាសហើយ តែនេះមានទាន់ព្រាត់ឯណា?

## បញ្ហាទី៣ : មូលបញ្ហានៃរឿង

មតិខ្ញុំទៅបានសំរេចថា មូលបញ្ហាស្ថិតនៅជុំវិញបញ្ហាកម្មផល ព្រោះចោទបញ្ហាខន្តីឬសន្តិភាពមិនច្បាស់លាស់ ។ ដូច្នេះយើងត្រូវពិនិត្យបញ្ហានេះបន្តិច ។

## បញ្ហាទី៤ : បញ្ហាកម្ម ផល

ក្នុងរឿង កវីបានបញ្ជាក់ថា អ្វីទាំងអស់សុទ្ធតែមកពី ''កម្ម'' ។ ដូច្នេះគ្មានតួណាមួយខុស គ្មានតួណាមួយត្រូវឡើយ ។ ទោះបីតួណាមួយធ្វើខុសយ៉ាងណាក្តី ក៏គ្មានត្រូវទទួលទោសដែរ ព្រោះគ្រាន់តែជាការជួយបំពេញការៈឲ្យតួមួយទៀតបានសោយ ''ផល

កម្ម»ប៉ុណ្ណោះ ។ បើនិយាយដូច្នេះ ក្រុងអសុកមិត្រ ដែលទៅកើតជាទេវទត្ត ក៏ពុំទាន់ជាសមរម្យដែរ ។

ការពិភាក្សា : ១– ក្រុងសុកមិត្រហាក់ដូចជាបណ្ដោយតែតាមកម្មជ្រុលពេកពុំសូវជាខំតស៊ូសោះ ។

២– ក្រុងអសុកមិត្រធ្វើអំពើក្បត់ ទៅជាបានសោយរាជក្នុងបច្ចុប្បន្នជាតិនេះ តែនឹងទទួលផលអាក្រក់ទៅក្នុងអនាគតជាតិវិញ ។ ត្រង់នេះជាហេតុនាំឲ្យជនខ្លះមិនញញើតនឹងធ្វើអំពើអាក្រក់ អំពើក្បត់ខ្លះ ព្រោះគេយល់ថា ជាតិនេះគេបានចុំចើង ឯជាតិខាងមុខដែលគេមើលមិនទាន់ឃើញនោះ គេពុំបានយកចិត្តទុកដាក់ព្រួយបារម្ភសោះ ។ ម្យ៉ាងទៀតការពឹងផ្អែកលើជំនឿកម្មផល អាចធ្វើឲ្យមនុស្សដែលកំពុងរងទុក្ខវេទនាខ្លះសុខចិត្តដេកត្រាំក្នុងអន្លង់ទុក្ខ ឥតខំរើបំរាស់ ព្រោះគេយល់ច្រឡំថា ទុកជាគេខំរំដោះទុក្ខយ៉ាងណាក៏មិនអាចសំរេចបាន គ្មាននរណាអាចប្រឆាំងនឹងផលកម្មបានឡើយ ។ ជំនឿក័ន្តច្រឡំបែបនេះអាចក្លាយទៅជាខែលបិទបាំង អំពើអាក្រក់ អំពើមនុស្សជិះជាន់មនុស្ស ហើយអាចឲ្យមនុស្សអាក្រក់បន្តសកម្មភាពអមនុស្សធម៌បានដោយងាយ ។

៣– ចំពោះពាក្យថា «កម្មផល» ។ ពាក្យនេះបើយកតាមន័យពិត ត្រឹមត្រូវណាស់ គឺអំពើធ្វើនឹងការទទួលផល ។ បើយល់តាមទ្រឹស្ដីថា «កម្មល្អឲ្យផលល្អ កម្មអាក្រក់ឲ្យផលអាក្រក់» នេះជាការប្រសើរណាស់ តែឲ្យធ្ងន់ខាងបច្ចុប្បន្នជាតិ ។

តាមភាសាសាមញ្ញ ពាក្យនេះមានន័យផ្សេង ។ គេច្រើនយកមកប្រើក្លាយពីន័យដើម ។ «ឲហេតុតែកម្មឯង» «កម្ម» នេះច្រើនសំដៅយកតែអំពីអាក្រក់ពីជាតិមុន ។ មហាជនរំពុកពាក្យនេះឡើង គ្រាន់តែជាការជួយសំរាលទុក្ខបានយ៉ាងតិចតួចស្ដួចស្ដើងប៉ុណ្ណោះ តែពុំអាចដោះស្រាយឲ្យបានស៊ីជំរៅដល់ឫសគល់នៃបញ្ហាណាមួយឡើយ ។ បានសេចក្ដីថា មិនបណ្ដោយតាម «កម្ម» ឬព្រេងវាសនាទេ ។

– ពេលកូនកើតមក មានរូបមិនធម្មតា ដើម្បីបិទបាំងកេរ្តិ៍ខ្មាស ឪពុកម្ដាយថា មក ពី "កម្ម" របស់កូន ។

– ពេលបាត់របស់ឬចោរលួចប្លន់ជាដើម ក៏គេថាមកពី "កម្ម" ។

– មានមហាជនខ្លះ រហូតដល់គេរំលោភធ្វើបាប បំផ្លាញព្រហ្មចារិនីកូន គេលួចសហាយភរិយា ឬគេព្យាបាទដល់រូបខ្លួនផ្ទាល់ ក៏នៅតែយល់ថាជា "កម្ម"ពីអតីត ... ។


**បណ្ណាគារ វិជ្ជាសាកល**

លេខ ២៥៧ វិថីព្រះបាទសីហនុ ភ្នំពេញ

**បណ្ណាគារ សុតមិត្រ**

លេខ ៣៦៧ C ផ្លូវកម្ពុជាក្រោម ភ្នំពេញ

មានសេចក្ដីរីករាយនឹងចុះថ្លៃ១០% ជូនមិត្តយើង ដែលទៅទិញ សៀវភៅខ្មែរ នៅបណ្ណាគារទាំងនេះ ហើយដែលបានបង្ហាញបណ្ណសមាជិកផង !

ចំណែកឯ

**បណ្ណាគារ ប៊ុត នាង**

លេខ ១៧៦ វិថីខេមរភូមិន្ទ ភ្នំពេញ

ក៏មានសេចក្ដីរីករាយនឹងចុះថ្លៃ ១០% ចំពោះសៀវភៅណាដែលផ្សាយចេញពីបណ្ណាគាររបស់ខ្លួនដែរ ។

សូមមិត្តអញ្ជើញទៅទិញ ដោយបង្ហាញបណ្ណសមាជិកផង !

# ប្រវត្តិវិទ្យា

ដោយយល់ឃើញថា ទស្សនាវដ្ដីយើងលេខនេះចេញមុនពេលប្រឡងសញ្ញាប័ត្រមធ្យមសិក្សាបន្តិច ហើយ ដោយចង់ឲ្យមិត្តយើងមានឯកសារមួយថែមទៀត ជាជំនួយក្នុងការបំភ្លឺសិស្សផង យើងបានសំរេចចិត្តចុះនូវមេរៀនប្រវត្តិវិទ្យាខាងក្រោមនេះថែមទៀត ។

## ការវិវត្តន៍

## ខាងផ្ទៃក្នុងនៃរដ្ឋកម្លាំងថ្មី

### ប្រទេសរុស្ស៊ី ពីឆ្នាំ 1917 ដល់ឆ្នាំ 1939

ដោយ ម៉ៃ លស់

### I– ការស្ដាបនានូវរបបរួមសំបាច់

*ក្នុងបណ្ដារដ្ឋនៅទ្វីបអឺរ៉ុបទាំងឡាយ ប្រទេសរុស្ស៊ីជាប្រទេសមួយដែលមានការប្រែប្រួលយ៉ាងសំបើមជាងគេ ។ មកទល់នឹងមហាសង្គ្រាមសកលលោកលើកទី ១ ប្រទេសរុស្ស៊ីជារាជាធិបតេយ្យ ហើយគ្រប់អំណាចរដ្ឋធ្លាក់មូលតែក្នុងព្រះហស្ដមហាក្សត្រមួយព្រះអង្គ ទោះបីមានរដ្ឋធម្មនុញ្ញតាំងពីឆ្នាំ 1905 មកក៏ដោយ ។*

*ក្នុងមួយរយៈយ៉ាងខ្លី គឺក្នុងសង្គ្រាម ប្រទេសរុស្ស៊ីបានប្រែជាសាធារណរដ្ឋរួមសំបាច់ ដែលលោកឡេនីន នឹងបក្សពួករបស់លោកជាអ្នកផ្ដើមគំនិត ផ្ដើមបដិវត្តក្នុងឆ្នាំ 1917 ។ លុះបានកាន់កាប់អំណាចភ្លាម ឡេនីននឹងបក្សពួកលោកបានធ្វើវិធានការជាច្រើន ដើម្បី*

បំបាត់របបគ្រប់គ្រងចាស់ក្នុងគ្រប់វិស័យ គឺក្នុងវិស័យនយោបាយ វិស័យសេដ្ឋកិច្ច និងវិស័យសង្គមកិច្ច ។ ប្រទេសរុស្ស៊ីបានប្រែឈ្មោះហៅថា សហភាពសាធារណរដ្ឋសង្គមនិយមសូវៀត ។

## II– ឧបសគ្គដែលរដ្ឋសូវៀតបានពើបប្រទះ

ក្រោយដែលរបបគ្រប់គ្រងថ្មីបានត្រូវស្ថាបនាឡើងដោយ បដិវត្តន៍ខែតុលា 1917 មក សហភាពសូវៀតបានពើបប្រទះនឹងឧបសគ្គ ហើយនឹងការលំបាកជាច្រើន ។ គេត្រូវប្រយុទ្ធតស៊ូគ្រប់បែបគ្រប់យ៉ាង ដើម្បីនឹងការពារបដិវត្តន៍ ពិសេសគឺប្រយុទ្ធទល់នឹងពួកប្រឆាំងបដិវត្តន៍ខាងផ្ទៃក្នុងរដ្ឋ ហើយនឹងអន្តរាគមន៍ពីបរទេស ដែលមានគោលបំណងនឹងសម្លាប់របបគ្រប់គ្រងថ្មី ។

### ក– ការប្រឆាំងនឹងការបដិវត្តន៍ខាងផ្ទៃក្នុងប្រទេស :

ក្នុងរយៈបីឆ្នាំ (ពីឆ្នាំ 1918 ដល់ឆ្នាំ 1921 ) សង្គ្រាមផ្ទៃក្នុងមួយបានកើតពាសពេញប្រទេស ។ សង្គ្រាមនេះបានបង្កបង្កើតឡើងដោយពួកប្រឆាំងនឹងការបដិវត្តន៍ ដែលគេហៅថា “ពួកស (les Blancs)” ដែលបានទទួលជំនួយនឹងការគាំទ្រយ៉ាងចំហពីពួកបក្សសម្ពន្ធចាស់របស់ប្រទេសរុស្ស៊ី ។ ឈមមុខនោះនឹងមហន្តរាយយ៉ាងខ្លាំងនេះ រដ្ឋាភិបាលកុម្មុយនីសសូវៀតបានចាត់វិធានការយ៉ាងតឹងរឹង ហើយបានប្រើគ្រប់មធ្យោបាយប្រយុទ្ធតទល់នឹងពួកបច្ចាមិត្តដ៏ឃោរឃៅនេះ ដើម្បីស្រោចស្រង់បដិវត្តន៍ ។

ជាអវសាន ពួកប្រឆាំងនឹងបដិវត្តន៍បានត្រូវកំទេចអស់រលីង ក្រោយពីការតស៊ូអស់រយៈវេលា ៣ ឆ្នាំបាយមក ។ ប៉ុន្តែរបបគ្រប់គ្រងថ្មីពុំទាន់ផុតគ្រោះថ្នាក់នៅឡើយទេ ។ គ្រោះថ្នាក់ក្រោយនេះជាគ្រោះថ្នាក់ធំណាស់ ហើយដែលបានបង្កបង្កើតឡើងដោយសត្រូវនឹងបដិវត្តន៍ខាងក្រៅប្រទេស ។

#### ១– អន្តរាគមន៍បរទេស :

សម្ពន្ធមិត្តចាស់របស់រុស្ស៊ីមិនសប្បាយចិត្តនឹងការស្ថាបនារបបគ្រប់គ្រងកុម្មុយនីសនៅ

សហភាពសូវៀតទេ ហើយចាំតែរកគ្រប់ឱកាសជាអនុគ្រោះដល់គេ ដើម្បីនឹងធ្វើអន្តរាគមន៍កំទេចនូវបដិវត្តន៍ចោល ។ ចំបាំងផ្ទៃក្នុងដែលពួកស បានបង្កបង្កើតឡើងនោះ បានអនុញ្ញាតឲ្យពួកបរទេសជាសត្រូវ ធ្វើអន្តរាគមន៍ចូលក្នុងកិច្ចការខាងផ្ទៃក្នុងនៃសហភាព-សូវៀត ។

កងទ័ពឆេក្កូបានលុកលុយដំបន់វ៉ុលហ្គា(Volga) ឯកងទ័ពអង់គ្លេស ដណ្តើមបានទីក្រុងអារខង់ហ្សែលស្គ៍(Arkhangelsk)។កងទ័ពបារាំងបានលុកលុយចូលក្រុងអូដេស្សា (Odessa) ទ័ពជប៉ុនវាយយកដំបន់វ្ល៉ាឌីវ៉ូស្តុក (Vladivostok) ឯកងទ័ពប៉ូឡូញវាយយកបានទីក្រុងគីយ៉េហ្វ (Kiev) ។ ចំពោះគ្រោះថ្នាក់ដ៏មហន្តរាយដែលកំហែងកំពមបដិវត្តន៍នេះ រដ្ឋាភិបាលសូវៀតបានប្រើអស់សមត្ថភាពរបស់ខ្លួន ដើម្បីវាយកំចាត់សត្រូវគ្រប់ទិសទី ។ " កងទ័ពក្រហមសូវៀត ( l'Armée Rouge )" ក្រោមការដឹកនាំផ្ទាល់របស់ឡេនីន បានធ្វើឲ្យបច្ចាមិត្តបរាជ័យគ្រប់សមរភូមិ ។ ឯរបបគ្រប់គ្រងកុម្មុយនីសក៏បានទទួលជោគជ័យយ៉ាងគ្រប់គ្រាន់ ក្រោយពីបានវាយទំលេចសត្រូវរបស់ខ្លួនចេញអស់ពីប្រទេសមក ។

## III – អំពើសំខាន់ៗទាំងឡាយដែលរបបគ្រប់គ្រងថ្មីបានធ្វើក្នុងឆ្នាំដំបូង

ក្រោយពីបានវាយកំទេចពួកប្រឆាំងនឹងបដិវត្តន៍ខាងផ្ទៃក្នុង ហើយនឹងអន្តរាគមន៍ពីបរទេសហើយ របបគ្រប់គ្រងថ្មីបានចាប់ផ្តើមចាត់វិធានការសំខាន់ៗទាំងឡាយ ដើម្បីនឹងកសាងសង្គមនិយមនៅក្នុងប្រទេសរុស្ស៊ី ដោយប្រកាន់ខ្ជាប់នូវគោលការណ៍ទាំងឡាយដូចតទៅ :

### ក– គោលការណ៍ទាំងឡាយនៃរបបគ្រប់គ្រងថ្មី :

ក្រោយពីបានរំលំរបបគ្រប់គ្រងចាស់មក គណៈបក្សបុលសេវិក(le Parti Bolchevik) ដែលមានលោកឡេនីន ជាអគ្គមគ្គុទេសក៍ បានរៀបចំរបៀបគ្រប់គ្រងថ្មីមួយ ដែលផ្អែក

ទៅលើគោលការណ៍សំខាន់ៗទាំងឡាយដូចតទៅ :

**ខាងក្នុងប្រទេស** : នៅឆ្នាំ 1918 សហភាពសាធារណរដ្ឋសង្គមនិយមសូវៀត បានប្រកាសឲ្យប្រើនូវរដ្ឋធម្មនុញ្ញមួយថ្មី ។ ដល់ឆ្នាំ 1924 រដ្ឋធម្មនុញ្ញទី១ត្រូវបានកែប្រែ ហើយក្នុងឆ្នាំ 1936 រដ្ឋធម្មនុញ្ញថ្មីមួយទៀតត្រូវបានយកមកប្រើ ដោយរដ្ឋធម្មនុញ្ញខាងលើ លែងមានលក្ខណៈស្របនឹងកាលៈទេសៈថ្មីនៃរដ្ឋសូវៀតទៀតហើយ ។ រដ្ឋធម្មនុញ្ញសូវៀត បានចែងក្នុងមាត្រាមួយថា : "សហភាពសាធារណរដ្ឋសង្គមនិយមសូវៀត ជារដ្ឋសង្គម-និយមរបស់កម្មករនឹងកសិករ" ។ អង្គការផ្សេងៗរបស់រដ្ឋគឺ :

– សភាសូវៀតជាន់ខ្ពស់ (le Soviet Suprême) ដែលចែកជាសភានៃសហភាពនឹងសភានៃសញ្ជាតិ (le Soviet de l'Union, le Soviet des Nationalités ) ។ សភាទាំងពីរនេះ ជាអង្គការនីតិបញ្ញត្តិ ។

– ក្រៅពីអង្គការជាន់ខ្ពស់ខាងលើ គឺមានសភាផ្សេងៗ ដូចជាសភានៃអ្នកតំណាងពលរដ្ឋនៅតាមអាណាចក្រ, អាណាចក្រស្វយ័ត, តាមខណ្ឌ, តាមក្រុង ឬតាមកេងចក្រៗ

– អង្គការកាន់អំណាចនីតិប្រតិបត្តិ គឺក្រុមអភិបាលនៃស្នងការប្រជាជន (សព្វថ្ងៃ គឺគណៈរដ្ឋមន្ត្រី) ។

ម្យ៉ាងទៀត រដ្ឋធម្មនុញ្ញបានប្រកាសឲ្យមានសមភាពដល់គ្រប់ពលរដ្ឋនៃសហភាពសូវៀត ដោយពុំគិតដល់ភេទ ដល់សញ្ជាតិនឹងសាសន៍ឡើយ ។ គោលការណ៍នយោបាយក្រៅប្រទេសសំខាន់នៃរបបគ្រប់គ្រងថ្មីក្នុងពេលនោះគឺ :

១– បញ្ឈប់ការធ្វើសង្គ្រាមតទៅទៀត

២– ស្នើឲ្យគ្រប់ប្រទេសដែលបានរួមក្នុងចំបាំង ចរចាអំពីយុទ្ធសន្តិភាព (l'armistice) ទូទៅ ។ ប៉ុន្តែការស្នើនេះ ពុំបានទទួលការយល់ព្រមពីបក្សសម្ពន្ធឡើយ ហើយប្រទេសរុស្ស៊ីក៏បានចុះហត្ថលេខាលើយុទ្ធសន្តិភាពដោយឡែកជាមួយនឹង អាល្លឺម៉ង់ នៅថ្ងៃ 15 ធ្នូ 1917 ។ នៅថ្ងៃទី 3 មីនា 1918 សន្ធិសញ្ញាសន្តិភាពមួយបានទទួលហត្ថលេខារវាង

ប្រទេសរុស្ស៊ី នឹងប្រទេសអាល្លឺម៉ង់ គឺសន្ធិសញ្ញា ប្រេស-លីតូវស្ក (Brest-Litowsk) ។

ម្យ៉ាងទៀត ចំពោះនយោបាយក្រៅប្រទេសទូទៅ សហភាពសាធារណរដ្ឋសង្គមនិយមសូវៀត បានប្រកាន់នូវគោលការណ៍នៃសហវិជ្ជមានដោយសន្តិភាព (la coexistence pacifique) ការទាក់ទងរវាងរដ្ឋនឹងរដ្ឋដោយសមភាព ។ល។

## ១- គោលការណ៍ខាងសេដ្ឋកិច្ច

ក្នុងវិស័យសេដ្ឋកិច្ច វិធានការសំខាន់ៗបានត្រូវយកមកអនុវត្តដើម្បីស្ថាបនាសង្គមថ្មីមួយប្រកបដោយសុចរិតយុត្តិធម៌ ពោលគឺបំបាត់ "អំពើជិះជាន់មនុស្ស" ។

គេអាចចែកការអនុវត្តន៍នូវកម្មវិធីសេដ្ឋកិច្ចថ្មីជាពីររយៈ:

– រយៈទី ១ ពីឆ្នាំ 1918 ដល់ឆ្នាំ 1924 គឺសហវិជ្ជមាននៃរបបសេដ្ឋកិច្ច មូលធននិយមឯកជននឹងសង្គមនិយម ។

ការអនុវត្តន៍ទាំងស្រុងនូវលទ្ធិសេដ្ឋកិច្ចកុម្មុយនីស ពោលគឺរដ្ឋកាន់កាប់ទាំងអស់នូវគ្រប់អង្គការសេដ្ឋកិច្ច បានហុចលទ្ធផលផ្ទុយពីការគ្រោងទុកជាមុន ដោយស្ថានភាពប្រទេសរុស្ស៊ី ក្រោយពីចំបាំងភ្លាមៗមិនមានលក្ខណៈជាអនុគ្រោះឡើយ ។ លោកឡេនីន ដោយយល់ច្បាស់នូវបញ្ហានេះ ក៏សំរេចកែប្រែកម្មវិធីសេដ្ឋកិច្ចខាងលើខ្លះៗ ដើម្បីលើកស្ទួយស្ថានភាពសេដ្ឋកិច្ចរដ្ឋ ។ យ៉ាងណាមិញ លោកបានបញ្ចូលនយោបាយសេដ្ឋកិច្ចថ្មី ដែលមានឈ្មោះហៅថា "នយោបាយថ្មីខាងសេដ្ឋកិច្ច" Nouvelle politique économique (NEP) ។ តាមគោលការណ៍នយោបាយនេះ រដ្ឋអនុញ្ញាតឲ្យមូលធននិកឯកជនម្នាក់ៗរកស៊ីបានខ្លះ ក្នុងផ្នែកសេដ្ឋកិច្ចណាដែលពុំមានសារៈសំខាន់ ។ ចំពោះផ្នែកសំខាន់ៗ រដ្ឋត្រូវកាន់កាប់តទៅទៀតដដែលដូចជា ឧស្សាហកម្មធំៗ ពាណិជ្ជកម្មក្រៅប្រទេសនឹងការដឹកនាំ ។

– រយៈ ទី២ ពីឆ្នាំ 1924 រហូតមកដល់បច្ចុប្បន្នសម័យ: ការអនុវត្តន៍នូវលទ្ធិសេដ្ឋកិច្ច

កុម្មុយនីសទាំងស្រុង ។

វិធានការដែលលោកឡេនីនបានអនុវត្ត បានហុចលទ្ធផលយ៉ាងពិស្តារ ដែលជាហេតុឲ្យគេចៀសវាងវិបត្តិបានក្នុងពេលនោះ ។ សកម្មភាពសេដ្ឋកិច្ចក៏មានដំណើររស់រវើកឡើងវិញ ប៉ុន្តែលោកឡេនីនបានទទួលអនិច្ចកម្មទៅ ក្នុងឆ្នាំ 1924 ដោយពុំទាន់បានឃើញយ៉ាងជាក់ច្បាស់នូវការលូតលាស់យ៉ាងឆាប់រហ័ស នៃការអនុវត្តន៍ផែនការរបស់លោក ។ លោក ស្តាលីន បានទទួលអំណាចតពីលោក ឡេនីន ។ គោលបំណងរបស់លោកគឺធ្វើឲ្យប្រទេសរុស្ស៊ី ដែលពីដើមរៀងមកផ្អែកតែទៅលើកសិកម្មនោះ ប្រែក្លាយទៅជាមហាប្រទេសឧស្សាហកម្មមួយដ៏ចំរើនសំបូណ៌សប្បាយ ។ លោកបានចាប់ផ្តើមធ្វើផែនការសេដ្ឋកិច្ចគ្រប់មែកធាងទាំងអស់ ។ រដ្ឋបានយកមកកាន់កាប់ឡើងវិញនូវគ្រប់សកម្មភាពសេដ្ឋកិច្ច ។ មូលធននិយមឯកជនត្រូវបានលុបចោលទាំងអស់ ។ ដំហានដំបូង ដើម្បីសំរេចគោលដៅខាងលើ គឺ :

១— ការធ្វើផែនការប្រាំឆ្នាំ :

ផែនការប្រាំឆ្នាំទី ១ ( 1928-1933 ) ផែនការប្រាំឆ្នាំទី២ ( 1933-1938 ) បានហុចលទ្ធផលយ៉ាងសំបើម ។ ស្ថានភាពសេដ្ឋកិច្ចបានឡើងមួយកំរិតខ្ពស់ ដែលគេពុំដែលបានជួបប្រទះសោះនៅប្រទេសរុស្ស៊ីតាំងពីដើមរៀងមក ។ រដ្ឋសូវៀតក៏ប្រែទៅជាអំណាចឧស្សាហកម្មមួយប្រៀបស្មើបាននឹងសហរដ្ឋអាមេរិក ។

ឆ្នាំ 1939 នៅពេលដែលរដ្ឋសូវៀតរៀបចំអនុវត្តនូវផែនការប្រាំឆ្នាំទី៣ មហាសង្គ្រាមសកលលោកលើកទី២បានផ្ទុះឡើងម្តងទៀត ជាហេតុដែលធ្វើឲ្យផែនការនោះពុំបានទទួលនូវការអនុវត្ត ។

២— សមូហភាវូបនីយកម្មនៃស្រែចំការ

ស្រែចំការទាំងឡាយត្រូវបានប្រមូលផ្តុំជាប្រជាសហគមន៍ ( kolkhoze ) ហើយរដ្ឋាភិបាលបានចែកឲ្យកសិករទាំងនោះនូវឧបករណ៍ផ្សេងៗ ដូចជា នង្គ័ល ត្រាក់ទ័រ ពូជ

ដំណាំ ឬក៏ឲយខ្ចីប្រាក់កាស ដើម្បីរកស៊ី ។

ស្របជាមួយនឹងសមូហកាវូបនីយកម្មនៃស្រែចំការរបស់កសិករនេះ រដ្ឋបានបង្កើតស្រែចំការរបស់ខ្លួនលើដីទាំងឡាយណា ដែលគេបោះបង់ចោលតាំងពីដើមរៀងមក ដែលគេហៅថា សូវខូហ្ស (Sovkhoze) ។ លទ្ធផលនៃការកែប្រែនេះ បានធ្វើឲយលទ្ធផលខាងកសិកម្មមានសន្ទុះលឿនយ៉ាងសំបើម ។

លទ្ធផលនៃការអនុវត្តន៍នូវគោលការណ៍ខាងសេដ្ឋកិច្ចបានទទួលជោគជ័យយ៉ាងសំបើម ។ សក្ខីភាពនៃការចំរើននេះ មានដូចតទៅ :

– តាំងពីឆ្នាំ 1933 មក ឧស្សាហកម្មបានកើនដល់ 238%

– ពាណិជ្ជកម្ម បានកើនពី 125 ទៅ 278%

– ផលទុនជាតិបានឡើងពី 45 កោដិកន្លះទៅ 105 កោដិរូប្លិ៍ក្នុងរវាង10ឆ្នាំ (1928-1939)

– ផលិតផលស្រូវសាលី-ស្ករ-ប្រេងកាតបានកើន១ទ្វេជា២ កប្បាសមួយជាបួន។ល។

## គ– គោលការណ៍វប្បធម៌និងខាងសង្គមកិច្ច :

១– ខាងវប្បធម៌ :

មូលដ្ឋាននៃវប្បធម៌ គឺស្ថិតនៅលើភពនិយម (réalisme) និងប្រលោមនិយមបដិវត្ត (romantisme révolutionnaire) លើមូលដ្ឋាននេះ វប្បធម៌របស់សូវៀត សំដៅទៅរកការអប់រំនូវសុទិដ្ឋិនិយម ចំពោះអនាគតមនុស្សជាតិ ការអប់រំខាងការស្ថាបនា និងការអប់រំឲយមានចិត្តភ្ញៀវក្លា ស្រឡាញ់យុត្តិធម៌ ការពារផលប្រយោជន៍រួម ។ល។

២– ខាងសង្គមកិច្ច :

រដ្ឋសូវៀតបានបំបាត់ចោលអស់នូវវណ្ណៈផ្សេងៗក្នុងសង្គមសូវៀត ហើយបានលើកដំកើងវណ្ណៈពលករ (ពលករខាងបញ្ញា និងពលករកាន់ហត្ថកម្ម) ដែលបានទទួលសេចក្តីធានាផ្សេងៗពីក្រសួងសន្តិសុខសង្គមជាតិដូចជា :

– មនុស្សម្នាក់ៗត្រូវមានការធ្វើ

– មនុស្សម្នាក់ៗត្រូវទទួលនូវសេចក្ដីធានាពីរដ្ឋចំពោះជរាភាព ឬចំពោះជំងឺ ។ល។ ម៉្យាងទៀត ការសិក្សាបានលូតលាស់រីកចំរើនយ៉ាងក្រៃលែងជាទីបំផុត ។ យ៉ាងណាមិញ ក្នុងឆ្នាំ 1917 មានប្រជាពលរដ្ឋចំនួន ១៣០ លាននាក់ដែលពុំចេះអាន ពុំចេះសរសេរ ។ ដល់ឆ្នាំ 1937 អ្នកមិនចេះអាន មិនចេះសរសេរ (ភាពមិនចេះអក្សរ) បានបាត់សាបសូន្យស្ទើរតែអស់រលីងពីក្នុងរដ្ឋសូវៀត ។

## សហភាពនៃសាធារណរដ្ឋសង្គមនិយមសូវៀត នាឆ្នាំ ១៩៣៩ :

លទ្ធផលនៃការផ្លាស់ប្ដូរខាងនយោបាយ ខាងសេដ្ឋកិច្ច និងខាងសង្គមដែលបានប្រែប្រួលឡើងរហូតមក តាំងពីការបដិវត្តន៍ខែតុលា ១៩១៧ បានធ្វើឲ្យសហភាពនៃសាធារណរដ្ឋសង្គមនិយមសូវៀតប្រែក្លាយទៅជាមហាអំណាចមួយយ៉ាងធំ ទាំងខាងឧស្សាហកម្ម ទាំងខាងសឹក និងខាងផ្លូវចិត្តទៀតផង ពោលគឺជាមហាអំណាចមួយ ដែលមានការរៀបចំនិងមានរបៀបរៀបរយពិសេសពិសាលជាងគេបំផុតក្នុងលោកយើងនេះ នៅពេលមុនសង្គ្រាមសាកលលោកលើកទី ២ ។ តែគ្មាននរណាម្នាក់ ក្រៅពីរដ្ឋសូវៀតខ្លួនឯង ឬរដ្ឋណាមួយ ទោះរដ្ឋអាល្លឺម៉ង់នេះឯងក៏ដោយ ក៏ពុំអាចស្មានឬប៉ាន់ដ៏ត្រឹមត្រូវនូវកម្លាំងពិតរបស់រដ្ឋសង្គមនិយមនេះដែរ ។

**បណ្ណាគារអន្តរជាតិ** 150 G មហាវិថីទេវុ ភ្នំពេញ

សូមអញ្ជើញ មិត្តសមាជិកនៃសមាគមសាស្ត្រាចារ្យខ្មែរទៅទិញសៀវភៅ នៅបណ្ណាគារនេះ !

រង្វាន់២០%នឹងមានផ្ញើជូនចំពោះមិត្តណាដែលទៅទិញ ហើយបានបង្ហាញបណ្ណសមាជិក ។

មានលក់សៀវភៅសិក្សា សៀវភៅប្រលោមលោកជាភាសាខ្មែរ និងជាភាសាបារាំង; មានលក់ទស្សនាវដ្ដីដែលផ្សាយចេញនៅប្រទេសចិន វៀតណាម និងនៅសហភាពសូវៀត ហើយនិងសៀវភៅសំពប់បណ្ដុះវប្បធម៌ទូទៅជាច្រើនមុខទៀតជាភាសាបារាំង និង “អេស្ប៉េរ៉ង់តូ” ព្រមទាំង ....... រូបតុក្កតាផង ។

# អត្ថបទអនុពាក្យ

រៀបរៀងដោយ ញិប ម៉ៅ

## រុក្ខទិវា

នៅឱកាសដែលសម្តេចឪទ្រង់បញ្ជាឲ្យរាជរដ្ឋាភិបាលប្រារព្ធរៀបចំពិធីរុក្ខទិវានេះឡើង មានប្រជាពលរដ្ឋខ្លះចេះតែនឹកឆ្ងល់ក្នុងចិត្ត ហើយចង់ដឹងនូវហិតប្រយោជន៍ ព្រោះខ្លួនមិនដែលប្រទះព្រឹត្តការណ៍នេះសោះ ។

តែប្រសិនបើយើងរិះគិតមើលទៅ យើងនឹងអស់សង្ស័យមិនខាន ដ្បិតពិធីរបៀបនេះជាទំនៀមទំលាប់របស់ខ្មែរតាំងពីបុរាណកាលរៀងមក ដូចជាបុណ្យដាំដើមពោធិព្រឹក្សដែលមានគោលបំណងផ្សាយដំនឿខាងព្រះពុទ្ធសាសនា ហើយនឹងផ្តល់ឥដ្ឋមនុញ្ញផល ដល់ពុទ្ធសាសនិកជន ដែលមានបសាទសទ្ធាជ្រះថ្លាចូលរួមក្នុងបុញ្ញកម្មនេះ ។

រីឯរុក្ខទិវាវិញចង់ញុំាងពលរដ្ឋឲ្យស្គាល់យ៉ាងប្រត្យក្សនូវអត្ថប្រយោជន៍នៃឈើក្នុងបច្ចុប្បន្នជាតិ ។ ឈើបំរើមនុស្សស្និទ្ធស្នាលណាស់ តាំងពីយើងចាកឧទររបស់មាតា រហូតដល់រំលាយខន្ធទៅវិញ ។ យើងតែងយកឈើមកធ្វើជាឧស លំនៅស្ថាន នឹងឧបករណ៍ផ្សេងៗជាដើម ។ ម្យ៉ាងទៀត ព្រៃឈើមានមុខងារជាអាថ៌កំបាំងខាងធ្វើឲ្យភ្លៀងធ្លាក់ នឹងទប់ទឹកកុំឲ្យជោរជន់លិចភូមិស្ថាន ដែលសាមញ្ញជនមិនងាយយល់ដល់ឡើយ ។ ម្ល៉ោះហើយ អ្នកបច្ចេកទេសតែងខំធ្លៀតយកថ្ងៃដាំកូនឈើថ្មីៗ ដើម្បីធ្វើជាភស្តុតាងពន្យល់អ្នកផងឲ្យលុះក្នុងវិទ្យាសាស្ត្ររបស់ខ្លួន ។ ក្រៅអំពីនេះ ព្រៃឈើជារមណីយដ្ឋានអាចទាក់ចិត្តនឹងបំពេញអារម្មណ៍ទេសចរទាំងឡាយឲ្យស្បើយល្ហើយទុក្ខ បានសុខក្សេមក្សាន្ត ។

ទោះបីមានគោលដៅប្លែកគ្នាក្តី ក៏វនប្បកម្មតាមប្រពៃណីឬតាមសម័យនិយម សុទ្ធតែមានសារៈសំខាន់ដូចគ្នា សមនឹងសុភាសិតឥណ្ឌាមួយថា "អ្នកណាបានដាំឈើមួយដើម មុននឹងស្លាប់ទៅ មិនបានរស់នៅឥតប្រយោជន៍ឡើយ" ។



● ........ ពីវិទ្យាល័យរាស្ត្រនិយមព្រះសីហនុ (តាខ្មៅ)

ក៏ដូចជាប្រជាពលរដ្ឋទាំងឡាយដែរ មិត្តសាស្ត្រាចារ្យយើងបានចូលរួមយ៉ាងសកម្មក្នុងការកសាងផែនការកីឡា សំរាប់ប្រទេសជាតិ ។

ក្រោមការណែនាំរបស់មិត្ត ស៊ុម ហុង នាយកវិទ្យាល័យរាស្ត្រនិយមព្រះសីហនុ តាខ្មៅ នឹងមិត្ត ពុំ ឆយ ចាងហ្វាងអនុវិទ្យាល័យជ័យវរ្ម័នទី៧ ដីឥដ្ឋ មិត្តនៃសាលាទាំងពីរនេះ បានប្រកួតបាល់បោះ បាល់ទះ ក្នុងរយៈពេលពីរលើក ។ ការប្រកួតលើកទី១ប្រព្រឹត្តទៅក្នុងវិទ្យាល័យរាស្ត្រនិយមព្រះសីហនុ តាខ្មៅ នាថ្ងៃ ១៩ ធ្នូ ១៩៦៥ លើកទី២ក្នុងអនុវិទ្យាល័យជ័យវរ្ម័នទី៧ នាថ្ងៃ ៣ មេសា ១៩៦៥ ។ ការប្រកួតទាំងនេះ សុទ្ធតែប្រកបដោយបរិយាកាសរីករាយ ស្និទ្ធស្នាលជានិច្ច ។ ក្រោយពេលប្រកួតមានពិធីជប់លៀងរិតចំណងមិត្តភាពយ៉ាងជិតស្និទ្ធជាទីបំផុត ។

● ........ ពីអនុវិទ្យាល័យព្រែកសណ្តែក (ព្រៃវែង)

កាលពីថ្ងៃទី ២១ មករា ១៩៦៥ មិត្តនៅអនុវិទ្យាល័យព្រែកសណ្តែក បាននាំគ្នាទៅប្រកួតបាល់ទាត់ ជាមិត្តភាព ជាមួយមិត្តអនុវិទ្យាល័យព្រៃដើមថ្នឹង ។ ក្រោយការប្រកួតមិត្តអនុវិទ្យាល័យព្រៃដើមថ្នឹង បានធ្វើពិធីជប់លៀងទទួលមិត្តជាភ្ញៀវ ក្នុងបរិយាកាសស្និទ្ធ

ស្នាលជាទីបំផុត អស់រយៈពេលកន្លះរាត្រី ។

មិត្តអនុវិទ្យាល័យព្រែកសណ្តែក នឹងមិត្តអនុវិទ្យាល័យព្រៃដើមថ្នឹង បានរួបរួមគ្នាទៅធ្វើការប្រកួតបាល់ជាមួយមិត្តអនុវិទ្យាល័យសួង កំពង់ចាម ក្នុងថ្ងៃ ២០-២១ កុម្ភៈ ១៩៦៥ ។ មិត្តអនុវិទ្យាល័យសួងបានរៀបចំពិធីជប់លៀងទទួលមិត្តជាភ្ញៀវយ៉ាងរីករាយជាទីបំផុត ដោយមានវង់ភ្លេងកំដរលុះត្រាដល់អាធ្រាត្រ ។

........ ពីវិទ្យាល័យព្រះបាទសុរាម្រិត (កំពង់ឆ្នាំង)

កាលពីថ្ងៃទី១៧មករា ១៩៦៥ មិត្តសាស្ត្រាចារ្យនិងបុគ្គលិកនៃវិទ្យាល័យព្រះបាទសុរាម្រិត បានប្រកួតកីឡាបាល់ទះជាមិត្តភាព ជាមួយនឹងមិត្តសាស្ត្រាចារ្យព្រមទាំងបុគ្គលិកនៃអនុវិទ្យាល័យសាលាលេខប្រាំ នៅមណ្ឌលកីឡាដ្ឋានក្រុង ។ មិត្តខាងសាលាលេខប្រាំបានឈ្នះ ២ សិត ទល់នឹង ១ ។ នៅពេលថ្ងៃត្រង់មានការជប់លៀងទទួលនៅវិទ្យាល័យព្រះបាទសុរាម្រិត ។ នៅក្នុងឱកាសនោះ មិត្ត ទៀវ កុមារ នឹងមិត្ត សេង ប៊ុនថន ជាចាងហ្វាងសាលាទាំងពីរ បានប្តូរវត្ថុជាអនុស្សាវរីយ៍ ក្រោមសូរទះដៃយ៉ាងរីករាយជាទីបំផុត អំពីសំណាក់មិត្តជាង ៧០ នាក់ ដែលបានចូលរួមក្នុងពិធីនេះ ។

........ ពីវិទ្យាល័យព្រះឧទ័យ (តាកែវ)

នៅក្នុងឆ្នាំសិក្សា ១៩៦៤-១៩៦៥ នេះ មិត្តទាំងឡាយនៅវិទ្យាល័យឧទ័យ នឹងមិត្តទាំងឡាយនៅវិទ្យាល័យសង្គមរាស្ត្រនិយមភ្នំពេញ បានប្រកួតកីឡាបាល់ទះជាមួយគ្នា ជាមិត្តភាពអស់រយៈពេលពីរលើក ។ ការប្រកួតលើកទី ១ ប្រព្រឹត្តទៅនៅវិទ្យាល័យព្រះឧទ័យ នាថ្ងៃ ២២ មីនា ១៩៦៥ ។ លើកទី ២ នៅវិទ្យាល័យសង្គមរាស្ត្រនិយម នាថ្ងៃ២៨ មីនា ១៩៦៥ ។ ឯជ័យជំនះបានទៅមិត្តវិទ្យាល័យព្រះឧទ័យជានិច្ច ។ ការប្រកួតសុទ្ធតែប្រព្រឹត្តទៅក្នុងបរិយាកាសរីករាយជាទីបំផុត ។

## ...... ពីវិទ្យាល័យព្រះឱទ័យមកទៀត

កាលពីថ្ងៃទី ៤ ខែមេសា ឆ្នាំ ១៩៦៤ មានប្រកួតកីឡាបាល់ទះ បាល់បោះជាមិត្តភាព រវាងក្រុមកីឡាការីវិទ្យាល័យព្រះឱទ័យ នឹងក្រុមកីឡាការី នៃអនុវិទ្យាល័យទាំងអស់ក្នុងខេត្ត នៅមណ្ឌលកីឡាដ្ឋានវិទ្យាល័យព្រះឱទ័យ ក្រោមអធិបតីភាពនៃសហជីវិន ឈឹម សំណាង នាយកវិទ្យាល័យ នឹងសហជីវិន ពាង ហ្វាង អនុវិទ្យាល័យទាំងអស់ ព្រមទាំងប្រធានក្រុមកីឡា នានា ។ រីឯលទ្ធផលមានដូចតទៅនេះ :

ក) កីឡាបាល់ទះ : វិទ្យាល័យព្រះឱទ័យមានជ័យជំនះ លើអនុវិទ្យាល័យព្រះសោមា នឹង

អនុវិទ្យាល័យចំបក់ ។

អនុវិទ្យាល័យចំបក់មានជ័យជំនះលើអនុវិទ្យាល័យសម្ដេចឪ ។

ខ) កីឡាបាល់បោះ : វិទ្យាល័យព្រះឱទ័យបានស្មើនឹងអនុវិទ្យាល័យសម្ដេចឪ ។

អនុវិទ្យាល័យគិរីវង់មានជ័យជំនះលើអនុវិទ្យាល័យសម្ដេចឪ ។

អនុវិទ្យាល័យចំបក់មានជ័យជំនះលើអនុវិទ្យាល័យព្រះសោមា ។

បន្ទាប់ពីការប្រកួតប្រជែងនោះមក ក្រុមបុគ្គលិកវិទ្យាល័យព្រះឱទ័យ មានរៀបចំពិធីជប់លៀងមួយយ៉ាងប្រណិតជូនដល់ក្រុមកីឡាការីនៃអនុវិទ្យាល័យទាំងអស់ ក្នុងបរិយាកាសដ៏ស្និតស្នាលបំផុត ជានិមិត្តរូបនៃការរឹតចំណងមិត្តភាព នឹងការប្រសិទ្ធិពរជ័យក្នុងឱកាសចូលឆ្នាំថ្មីនេះ ។

## ......... ពីវិទ្យាល័យតេះតមកទៀត

តាមសេចក្ដីស្នើនៃមិត្ត *ឈឹម សំណាង* នាយកវិទ្យាល័យនឹងតំណាង ស.ស.១ យើងមានសេចក្ដីរីករាយនឹងចុះផ្សាយនូវពាក្យសព្ទសាធុការនេះ

# ពរចូលឆ្នាំថ្មីពីមិត្តវិទ្យាល័យព្រះឧទ័យ

ក្នុងឱកាសចូលឆ្នាំថ្មីនេះ មិត្តទាំងអស់នៅវិទ្យាល័យព្រះឧទ័យតាកែវ មានសេចក្តីរីករាយ សូមប្រសិទ្ធិពរជ័យសួស្តីសិរីមង្គលវិបុលសុខ ចំពោះមិត្តបុគ្គលិកសិក្សាក្នុងអាណាចក្រកម្ពុជា ជាពិសេស ចំពោះមិត្តសមាជិក សមាគមសាស្ត្រាចារ្យខ្មែរ ។

សូមឲ្យបំណងមិត្តភាព នឹងសាមគ្គីភាពរវាងបុគ្គលិកសិក្សានឹងបុគ្គលិកសិក្សា មានការរីកចំរើននឹងស្ថិរភាពជានិរន្តរ៍ ។

សូមឲ្យមានប្រសិទ្ធិភាព នឹងលទ្ធភាព ក្នុងការប្រកបការងារគ្រប់យ៉ាង ដើម្បីបំរើជាតិមាតុភូមិក្រោមព្រះរាជនយោបាយដ៏ភ្លឺស្វាងនៃសម្តេចឪ ។

## ......... ពីអនុវិទ្យាល័យសម្តេចព្រះឧបយុវរាជ (កំពង់ក្តី)

កាលពីថ្ងៃសៅរ៍ទី ២៧ កុម្ភៈ ដើម្បីពង្រីកមិត្តភាពបុគ្គលិកអនុវិទ្យាល័យសម្តេចព្រះឧបយុវរាជ កំពង់ក្តីបានប្រកួតកីឡាបាល់ទះជាមួយក្រុមគ្រូបឋមសិក្សា កំពង់ក្តី នៅទីលានកីឡាបឋមសិក្សា ។ បានអញ្ជើញមកជួយអបអរក្នុងពេលប្រកួត មានលោកគ្រូ-អ្នកគ្រូ អស់លោកមន្ត្រីរាជការក្នុងស្រុកព្រមទាំងសិស្សានុសិស្សជាច្រើន ។

ការប្រកួតដ៏ស្វិតស្វាញបានចប់សព្វគ្រប់នៅពេលម៉ោង ៥ កន្លះ ក្នុងបរិយាកាសយ៉ាងស្និទ្ធស្នាល ។ ជ័យជំនះបានទៅខាងមិត្តនៃអនុវិទ្យាល័យ ។

សូមមិត្តបញ្ជូនដំណឹងសុខទុក្ខនៃមិត្តយើង ក្នុងអគារនីមួយៗ មកគណៈកម្មាធិការនាយក ដើម្បីនឹងបានជាពត៌មានដល់មិត្តយើងឯទៀតៗផង ។

# ដំណឹងមិត្តយើង

## ដំណឹងផ្លាស់ប្តូរ

- មិត្តកញ្ញា ឆ្នូក វ៉ាន់ណារ៉េត បានផ្លាស់ពីវិទ្យាល័យសុរិយាវង្សទី២ មកវិទ្យាល័យទៅ ពញាយ៉ាត (ភ្នំពេញ)
- មិត្ត ហោ សេងហាក់ ចាងហ្វាងអនុវិទ្យាល័យសម្ដេចព្រះឧបយុវរាជ កំពង់ក្ដី នឹងតំណាង ស.ស.១ ត្រូវបានផ្លាស់ទៅវិទ្យាល័យសុរិយាវង្សទី២ សៀមរាប

– មិត្ត សុខ សូផាត សាស្ត្រាចារ្យនៃអនុវិទ្យាល័យដដែលនេះបានឡើងជាចាងហ្វាង នឹងតំណាង ស.ស.១ ផង ។

## ដំណឹងអាពាហ៍ពិពាហ៍

- កាលពីថ្ងៃ ១៤ មីនា ១៩៦៥ មិត្ត ជា ម៉ៃ សាស្ត្រាចារ្យនៅវិទ្យាល័យសុរិយាវង្សទី ២ សៀមរាប បានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងនាង អ៊ឹង រ៉ម នៅសៀមរាបដែរ ។ ចំពោះមង្គលការនេះ មិត្តយើងជាច្រើនបានទៅចំរើនពរជ័យដល់គូស្វាមីភរិយាថ្មីនេះយ៉ាងរីករាយ ។
- នៅឯក្រុងព្រៃវែង ក្នុងភោជនីយដ្ឋាន ហេង-អា មិត្ត ឃួន សាអ៊ឹម នៅអនុវិទ្យាល័យព្រែកសណ្ដែកបានរៀបអាពាហ៍ពិពាហ៍ជាមួយនាងកញ្ញា ដោក សុភាព កាលពីថ្ងៃ ២៧-២-៦៥ ។

យើងសូមប្រសិទ្ធិពរឲ្យគូសង្សារថ្មីនេះបានប្រកបតែនឹងសេចក្ដីសុខចំរើនសមតាមប្រាថ្នា ។

# កូនសៀវភៅពណ៌កុលាប

*កំណត់នៃគណៈនិពន្ធ.–*

រហូតមកទល់នឹងពេលនេះ ដូចអស់មិត្តបានឃើញស្រាប់ យើងតែងតែចុះនូវព័ត៌មានសព្វបែបសព្វយ៉ាងអំពីមិត្តយើង មានទាំងដំណឹងសំរាលកូនផង ក្នុងបំណងនឹងចង់ធ្វើឲយមិត្តទាំងឡាយបានដឹងសុខទុក្ខគ្នាជាហូរហែ ។ ប៉ុន្តែមើលៗទៅ ដំណឹងនេះហាក់ដូចជាដដែលៗ ហើយហាក់ដូចជាមិនទាំងតាំឲយសំរេចបំណងខាងលើបានប៉ុន្មានផង ។ ដូចនេះ ប្រសិនបើមិត្តមិនយល់ទាស់ទេ ចាប់ពីលេខក្រោយទៅ យើងសូមស្នើបិទទំព័រនេះចោល ហើយសូមមិត្តតំណាងមេត្តាជ្រាបអំពីការនេះផង ក្នុងការផ្ញើដំណឹងមកយើងនៅពេលក្រោយ ។

សូមអរគុណ

*ពិតមែនតែជាបន្ទុកមួយក៏ដោយ ក៏ទារកទារិកាជាសុភមង្គលរបស់គ្រួសារនិមួយៗដែរ មានគ្រួសារមិត្តយើងជាដើម ។*

● *កាលពីថ្ងៃ ២២ មីនា ១៩៦៥ អ្នកស្រី សរ ថៃសេង តំណាងអនុវិទ្យាល័យព្រះនរោត្តម បានសំរាលកូនស្រីមួយនៅមន្ទីរពេទ្យកាលម៉ែត ។ ជាបន្ទាប់នោះមិត្តគណៈកម្មាធិការនាយក បានទៅសួរសុខទុក្ខនិងសម្តែងសេចក្តីអបអរសាទរចំពោះទារិកានេះ ព្រមទាំងមានផ្លែឈើបន្តិចបន្តួចជាមួយផង ។*

● *នៅមន្ទីរពេទ្យ "បុប្ផាកួង" មិត្ត ឃាន ម៉ី នៅវិទ្យាស្ថានជាតិគរុកោសល្យខាងគណិត-វិទ្យា ឆ្នាំទី២ទើបនឹងបានកូនស្រីមួយកាលពីថ្ងៃព្រហស្បតិ៍ទី ២៥ កុម្ភៈ ១៩៦៥ ។ សុខភាពមាតានិងទារិកា ពុំមានអ្វីជាការព្រួយបារម្ភឡើយ ។*

● មិត្ត លី គីមអ៊ី *(ដំណាង)*, គីម ហុក, ឱប យេត, កេត សារុន *បានឆ្លៀតពេលទៅសួរសុខទុក្ខភរិយារបស់មិត្ត* ស៊ឹម សៀវ ប៉ារ *នៅផ្សារទេដុង ដែលទើបនឹងឆ្លងទន្លេ ព្រមទាំងទិញឥវ៉ាន់ផ្សេងៗ យកទៅជូនដៃបុត្រនេះផង ។*

● ដូចពេលមុនមិត្តសេង ប៊ុនថន បានបបួលមិត្តវ៉ូវ វ៉ួន, ស្រី សាអាត, ឯម ប៊ុនរេន និង ឌុង គឹមភៀវ ទៅសួរសុខទុក្ខភរិយាមិត្ត មីន ហេង-យៀង ដែលទើបនឹងសំរាលកូន បានកូនស្រីមួយនៅគេហដ្ឋាន ព្រមទាំងបានទិញរបស់ផ្សេងៗទៅចងដៃទារិកានេះផង ។

● កាលពីថ្ងៃទី ២២ មីនា ១៩៦៤ ភរិយារបស់មិត្ត អាំង ជិនលន់ សាស្ត្រាចារ្យវិទ្យាល័យសុរិយាវង្ស ទី ២ ទើបនឹងសំរាលកូនប្រុសមួយប្រកបដោយសេចក្ដីសុខសប្បាយ ។

● នៅឯកំពង់ធំ មិត្ត ម៉ៅ សាពឿន ទើបនឹងបានបុត្រមួយក្នុងខែមេសានេះ ។

● ចំណែកឯមិត្ត ឌរ ចុង សាស្ត្រាចារ្យអនុវិទ្យាល័យសម្ដេចឧបយុវរាជ កំពង់ក្ដី សៀមរាបវិញ ក៏មានភ័ព្វសំណាងនឹងទទួលកូនស្រីមួយដែរ (ជាលើកដំបូង) ក្នុងខែមីនា ដែលកន្លងផុតមកនេះ នាមន្ទីរពេទ្យសៀមរាប ។

យើងសូមប្រសិទ្ធិពរឲ្យទារកទារិកាទាំងនេះ ប្រកបតែនឹងសេចក្ដីសុខចំរើនតរៀងទៅ ហើយសូមសរសើរដល់មិត្តទាំងឡាយ ដែលបានខ្វល់ខ្វាយពង្រីកមិត្តភាព ដោយបានសួរសុខទុក្ខមិត្តយើងក្នុងបញ្ហានេះ ។

## ពីអនុវិទ្យាល័យជម្ពូវ័ន្ត

យើងបានទទួលដំណឹងថា មិត្ត ម៉ក់ឆាន់-ណាត សាស្ត្រាចារ្យអនុវិទ្យាល័យជម្ពូវ័ន្ត បានមកព្យាបាលរោគរបស់ខ្លួននៅមន្ទីរពេទ្យ-សូវៀត បន្ទប់លេខ ១៩៥ ។

នៅពេលនោះ ដើម្បីតែបំណងមិត្តភាពរវាងបងប្អូនយើង មិត្តគណៈកម្មាធិការនាយកពីរនាក់ (មិត្តឡុក វ៉ែន និង មាស ឌឹម) បានទៅសួរសុខទុក្ខ ...... ដល់មិត្តយើង ។

## ពីវិទ្យាល័យ កំពង់ធំ

យើងបានទទួលដំណឹងដោយក្រៀមក្រំថា ក្មួយរបស់មិត្ត នេត សែប ឈ្មោះ ម៉ី ធឿន ធ្វើគ្រូបង្រៀននៅខេត្តស្ទឹងត្រែង បានទទួលមរណភាពនៅចុងខែមីនានេះ ។

ដើម្បីជួយសំរាលទុក្ខនេះ មិត្តយើងនៅវិទ្យាល័យកំពង់ធំបានរួបរួមគ្នាចូលជាភាគទាន ប្រគល់ជូនដល់មិត្ត នេត សែប ។

## ពីវិទ្យាស្ថានជាតិគរុកោសល្យ

មិត្ត មាយ ម៉ារិន និស្សិតសាស្ត្រាចារ្យផ្នែកខ្មែរឆ្នាំទី២ ទើបនឹងបានបាត់បង់ជីតារបស់ខ្លួន (លោកតា តៀក ខាវ) ជន្មាយុ ៨៥ឆ្នាំ កាលពីថ្ងៃ១៤មេសា ១៩៦៥ ឃុំស្វាយប៉ោ ស្រុកសង្កែ (បាត់ដំបង) ដោយជរាពាធ ។ មិត្តរួមថ្នាក់បានអង្គាសប្រាក់ចូលជាវិភាគទានដល់មិត្តនេះ ដើម្បីជាសញ្ញានៃសាមគ្គីភាពផង និងដើម្បីជួយរំលែកទុក្ខរបស់មិត្តផង ។

គណៈកម្មាធិការនាយកនៃសមាគមយើង សូមរំលែកទុក្ខពីមិត្ត នេត សែប និងមិត្ត មាយ ម៉ារិន ហើយសូមសរសើរដល់គំនិតសង្គ្រោះគ្នា ដែលគួរយកទុកជាគំរូបានរបស់មិត្តនៅវិទ្យាល័យកំពង់ធំ និងវិទ្យាស្ថានជាតិគរុកោសល្យនេះ ដែលមានមិត្ត ម៉ម ណៃ និងមិត្ត កង សារ៉ន ជាតំណាង ។


## បណ្ណាគារ នាង ឆ្រុត សំបូណ៌

លេខ 78 វិថីព្រៃនគរ ភ្នំពេញ

មានសេចក្ដីរីករាយនឹងចុះថ្លៃយ៉ាងគាប់ចិត្ត ជូនសមាជិកសមាគមសាស្ត្រាចារ្យខ្មែរ ដែលអញ្ជើញទៅទិញសៀវភៅនៅបណ្ណាគារនេះ ។ និងមានចុះថ្លៃជូនជាពិសេសថែមទៀត ចំពោះសៀវភៅទាំងឡាយណាដែលអស់លោកសាស្ត្រាចារ្យមកបញ្ជាទិញ (នៅប្រទេសបារាំង) ដោយរួមគ្នាច្រើននាក់ ។

សូមបង្ហាញបណ្ណសមាជិក !

.... តាមគណៈកម្មាធិការនាយកបានទទួលនូវប្រាក់ភាគទានពី៖

[illegible]

| | | | |
|---|---|---|---|
| 1. | អនុវិទ្យាល័យ | សន្តិភាព | 500 រៀល |
| 2. | — | ជម្ពូវ័ន្ត | 200 — |
| 3. | — | ពារាំង | 160 — |
| 4. | — | សាលាលេខ ៥ | 490 — |
| 5. | វិទ្យាល័យ | រាស្ត្រនិយមព្រះសីហនុ (តាខ្មៅ) | 1360 — |
| 6. | — | ព្រះសុរាម្រិត | 1305 — |
| 7. | — | កំពង់ធំ | 200 — |
| 8. | វិទ្យាស្ថានជាតិគរុកោសល្យ (និ.សា.) | | 4040 — |
| 9. | វិទ្យាល័យ | ឥន្ទ្រទេវី | 420 — |
| 10. | — | ព្រះមុនិវង្ស | 900 — |
| 11. | អនុវិទ្យាល័យ | សាលាលេខ ៥ | 320 — |
| 12. | — | សម្តេចឪ (ត្រាំកក់ តាកែវ) | 1020 — |
| 13. | វិទ្យាល័យ | សង្គមរាស្ត្រនិយម (ភ្នំពេញ) | 280 — |
| 14. | — | សុរិយោវង្ស | 1079 — |
| 15. | អនុវិទ្យាល័យ | រស្មីសោភ័ណ | 740 — |
| 16. | — | ពាមជីកង | 332 — |
| 17. | — | សម្តេចព្រះឧបយុវរាជ (កំពង់ក្តីសៀមរាប) | 690 — |
| 18. | — | ព្រះរាជបូជនិយកិច្ច (ស្ទឹងត្រែង) | 770 — |
| 19. | វិទ្យាល័យ | ឥន្ទ្រទេវី | 420 — |
| 20. | — | ជ័យ | 1000 — |
| 21. | — | សុរិយាវ័ន្តទី ២ | 2000 — |
| 22. | — | ស៊ីសុវត្ថិ | 1080 — |
| 23. | អនុវិទ្យាល័យ | ទឹកឃ្លាំង | 540 — |
| 24. | — | ជម្ពូវ័ន្ត | 600 — |
| 25. | វិទ្យាស្ថានជាតិគរុកោសល្យ (និ.សា) | | 2000 — |
| 26. | វិទ្យាល័យ | កំពង់ធំ | 500 — |




## ● ប្រទេសចិនសាកគ្រាប់បែកបរមាណូប្រកបដោយជោគជ័យ

កាលពីថ្ងៃ ១៦ តុលា ១៩៦៤ វេលាម៉ោង ១៥ ប្រទេសចិនបានសាកគ្រាប់បែកបរមាណូមួយ នៅប៉ែកខាងលិចនៃប្រទេសប្រកបដោយជោគជ័យ ។ នេះជាជ័យជំនះមួយយ៉ាងមហាសារប្រយោជន៍របស់ប្រជាជនចិនក្នុងការការពារប្រទេសរបស់ខ្លួន និងក្នុងការវាយបង្ក្រាបនូវការគំរាមកំហែងរបស់ចក្រពត្តិនិយម ដែលចេះតែទន្ទ្រាញមិនដាច់ពីមាត់ ខ្លួននឹងប្រើអាវុធបរមាណូ ។

នៅក្នុងថ្ងៃដដែលនោះ ប្រទេសចិនបានចេញសេចក្ដីថ្លែងការណ៍មួយ បញ្ជាក់ឥរិយាបថរបស់ខ្លួនចំពោះបញ្ហាអាវុធបរមាណូនេះ ដោយមានបែងជាអាទិ៍ថា ប្រទេសចិនតាមតារទុយលុបបំបាត់ចោលជានិច្ចនូវអាវុធបរមាណូសព្វបែបយ៉ាង ហើយថាប្រសិនបើការនេះអាចធ្វើទៅបាននោះ ប្រទេសចិនមិនចាំបាច់ត្រូវការធ្វើការសាកល្បងនេះទេ ។ ថាប្រទេសចិនដែលធ្វើការសាកល្បងនេះ មិនមែនដោយជឿលើមហិទ្ធិឫទ្ធិរបស់វា ឬក៏ដោយចង់ប្រើវាទេ, ប៉ុន្តែគឺដោយចង់បំបាត់ចោលនូវភាពផ្ដាច់មុខរបស់មហាអំណាចបរមាណូ

ហើយនឹងបង់បំបាត់ចោលនូវអាវុធនេះតែប៉ុណ្ណោះ ពីព្រោះគេយល់តាមប្រសាសន៍របស់លោក មៅ សេទុង ថា "គ្រាប់បែកបរមាណូគឺជាខ្លាក្រដាស" ។

## • តែក្នុង១០ថ្ងៃ អាចឈប់ជក់បារីបាន

ផលិតផលអាមេរិកាំងថ្មីនេះមានឈ្មោះថា ប៉ារ៉ាហ្វូម៉ុល (parafomol) ផ្សំឡើងដោយសាររុក្ខជាតិ ។ ផលិតផលនេះមានគុណភាពអាចបំបាត់បន្តិចម្តងៗ នឹងជាស្ពាពនូវសេចក្តីត្រូវការខាងជាតិនីកូទីន (Nicotine) ដែលអ្នកជក់បារីមានការជាប់ជំពាក់ចិត្ត ។

ដោយសារកម្លាំងពេញលេញខាងការបន្សាបជាតិពុល នឹងដោយសារការផ្សំតាមធម្មជាតិយ៉ាងម៉ត់ចត់គ្មានជាតិជាទោសដល់តិចតួចសោះ ប៉ារ៉ាហ្វូម៉ុល ជាជោគជ័យមួយយ៉ាងសំខាន់ខាងវិទ្យាសាស្ត្រ បើប្រៀបធៀបទៅនឹងថ្នាំដទៃទៀត សំរាប់ប្រឆាំងនឹងសេចក្តីត្រូវការខាងជាតិនីកូទីន ។ ការពិសោធន៍នៅអឺរ៉ុប នឹងនៅសហរដ្ឋអាមេរិក បានបញ្ជាក់ថា ប៉ារ៉ាហ្វូម៉ុល បានទទួលជោគជ័យក្នុងពេលដែលថ្នាំដទៃទៀតពុំបានសំរេច ។

ដោយសារផលិតផលយ៉ាងជាក់ស្តែង ការលក់ប៉ារ៉ាហ្វូម៉ុល អាចប្រព្រឹត្តទៅដោយមានកិច្ចសន្យាសងវិញទាំងស្រុង ក្នុងករណីដែលថ្នាំនេះពុំបានសំរេចដូចបំណង ។

ដូច្នេះគួរតែប្រើថ្នាំទំនើបនេះ ល្បងមើលពីព្រោះវាអាចកំចាត់ក្រោយរយៈពេលពីរឬបីថ្ងៃ នូវទំលាប់ជក់បារី ទោះបីទំលាប់នោះមានលក្ខណៈយ៉ាងណាក៏ដោយ ។

ប្រសិនបើមិត្តចង់ចំរើនអាយុនឹងសុខភាព សូមសរសេរទាក់អាសយដ្ឋានខាងក្រោមនេះ

Institut de Défense contre les Méfaits du Tabac

service S 2-28, rue Saint-Charles, PARIS (15)

# មាតិការឿងៈ


- Nouvel An — a - d
- ការសិក្សានៅប្រទេសកូរ៉េប្រជាធិបតេយ្យប្រជាមានិត — 2
- ប្រទេសអាល្លឺម៉ង់ពីឆ្នាំ 1919 ដល់ 1939 ម៉ៃ លន់ — 11
- គ្រុនសន្ធំ ម៉ម ណៃ — 20
- សិក្សា "ក្រុងសុភមិត្រ" និស្សិតសាស្ត្រាចារ្យឆ្នាំទី២ — 24
- ប្រទេសរុស្ស៊ីពីឆ្នាំ 1917 ដល់ 1939 ម៉ៃ លន់ — 35
- រុក្ខទិវា ញ៉ុប មៅ — 43
- ស្នូរជួងសាលា — 44
- ជីវភាពមិត្តយើង — 48
- វិទ្យាសាស្ត្រ — 53



**ខេមរបណ្ណាគារ**

លេខ 174 វិថីខេមរភូមិន្ទ ភ្នំពេញ

មានសេចក្តីរីករាយនឹងចុះថ្លៃ15% បំពោះសៀវភៅខ្មែរ ជូនដល់មិត្តណាដែលទៅទិញសៀវភៅខ្មែរនៅបណ្ណាគារនេះ ហើយដែលបានបង្ហាញបណ្ណសមាជិកផង !




បើមិត្តសមាជិក ស.ស. ១ កាន់
ប័ណ្ណសមាជិកទៅទិញខោ អាវនៅ
ហាងនេះ ហាងនេះ មានសេចក្ដី
រីករាយ ហើយនឹងកិត្តិយសនឹងចុះ
ថ្លៃជូនមិត្តយ៉ាងពេញចិត្ត ។
សូមអញ្ជើញសាកមើល!

១ លេខ : ១៥ រៀល